## រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សេចក្តីណែនាំបច្ចេកទេស

# ស្តីពី

# ការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

**ខែ មីនា ឆ្នាំ ២០១៧**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងផែនការ

ក្រសួងមហាផ្ទៃ

លេខ : ០៧៦ ផក.

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការដាក់ឲ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេស
## ស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត និងក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១៧ នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យោងតាមស្មារតីកិច្ចប្រជុំលើកទី១៣របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧។

## សម្រេច

**ប្រការ ១.-**

ដាក់ឲ្យប្រើប្រាស់ "**សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក**"។

**ប្រការ ២.-**

ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក និងក្រុមការងារកសាងផែនការស្រុក ត្រូវរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ស្របតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកឲ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាដោយមានការយកចិត្តទុកដាក់លើបញ្ហាបរិយាប័ន្ន សមធម៌សង្គម និងការប្រែប្រួលអាកាសធាតុ។

**ប្រការ ៣.-**

ក្រសួងផែនការ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រដល់រដ្ឋបាលស្រុក ដើម្បីឲ្យរដ្ឋបាលស្រុកមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសនេះ សម្រាប់ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

ក្រសួងផែនការ ក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រាជកិច្ច
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

# មាតិកា

## ផ្នែកទី១
## និន្នាការទូទៅនៃការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក


១. អត្ថន័យនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល ១
២. គោលការណ៍ ១
៣. យន្តការ និងភារកិច្ច ១


## ផ្នែកទី២
## ទម្រង់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក


១. ក្របមុខ ៥
២. មាតិកាសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ៦
៣. សេចក្តីពន្យល់អំពីបណ្តាសមាសធាតុនៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ៧


## ផ្នែកទី៣
## វិធីសាស្ត្ររៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំ រំកិលស្រុក


ជំហានទី១ ៖ ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ១៥
ជំហានទី២ ៖ ការរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ១៨
ជំហានទី៣ ៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ៣០


## ផ្នែកទី៤
## ឧបសម្ព័ន្ធជាជំនួយស្មារតី
## នៅពេលរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក


ឧបសម្ព័ន្ធទី១ ៖ ទម្រង់សេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ៣៣
ឧបសម្ព័ន្ធទី២ ៖ ទម្រង់ធាតុចូល ៣៤
ឧបសម្ព័ន្ធទី៣ ៖ វិធីសាស្ត្រចាត់អាទិភាព ៣៩
ឧបសម្ព័ន្ធទី៤ ៖ វិធីសាស្ត្រវិភាគស្ថានភាព ៤០
ឧបសម្ព័ន្ធទី៥ ៖ ចំណុចគន្លឹះសម្រាប់ក្រុមប្រឹក្សា ៤១
ឧបសម្ព័ន្ធទី៦ ៖ ជំនួយស្មារតីសម្រាប់ការរៀបចំសរសេរស្ថានភាពទូទៅ ៤២
ឧបសម្ព័ន្ធទី៧ ៖ ឧបករណ៍វិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ៤៦

# ផ្នែកទី១

# ទិដ្ឋភាពទូទៅនៃការរៀបចំ និងកសាងកម្មវិធី
# វិនិយោគបីឆ្នាំរំកិលស្រុក

# ឥដ្ឋភាពទូទៅ
# នៃការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

## ១. អត្ថន័យនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក គឺជាការដែលធ្វើឱ្យខ្លឹមសារនៃផែនការអភិវឌ្ឍន៍ស្រុកទៅជាសកម្មភាព ឬសេវាជាក់ស្តែង ដោយមានភ្ជាប់នូវចំណាយមូលនិធិ សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍនៅក្នុងស្រុក សម្រាប់រយៈពេលបីឆ្នាំ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

កម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកឆ្លុះបញ្ចាំងពីគម្រោង ឬសេវាជាអាទិភាពនិងតម្លៃតាមបណ្តាឆ្នាំនីមួយៗក្នុងរយៈពេលបីឆ្នាំ ស្របនឹងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម(បីឆ្នាំ)របស់រដ្ឋបាលស្រុក។ ពាក្យថា "បីឆ្នាំរំកិល" មានន័យថា កម្មវិធីវិនិយោគត្រូវរៀបចំឡើងសម្រាប់រយៈពេលបីឆ្នាំ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ ការរៀបចំបែបនេះ នាំមកនូវភាពងាយស្រួលក្នុងការបង្ហាញពីអ្វីដែលបម្រុងនឹងអនុវត្តនៅឆ្នាំខាងមុខ។

គម្រោង សកម្មភាពវិនិយោគ គឺជាគម្រោង សកម្មភាពត្រូវចំណាយមូលនិធិដោយមានពេលចាប់ផ្តើម និងពេលបញ្ចប់ច្បាស់លាស់ ដែលរៀបចំឡើងដើម្បីបង្កើតទ្រព្យសម្បត្តិសាធារណៈ (ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអរូបវន្ត) និងសេវានានាសម្រាប់ឆ្លើយតបតាមតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ។

## ២. គោលការណ៍

ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ត្រូវផ្អែកលើគោលការណ៍សំខាន់ដូចខាងក្រោម ៖

១. ការចែករំលែកព័ត៌មាន

២. តម្លាភាព

៣. សង្គតិភាព និងសុខដុមនីយកម្ម

៤. ការចូលរួមពិគ្រោះយោបល់ជាទូទៅ

៥. ការឆ្លើយតបនឹងតម្រូវការ

៦. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

៧. ប្រសិទ្ធភាព និងសុក្រឹត្យភាពសេដ្ឋកិច្ច និងសង្គម

៨. ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន

៩. ការធានាសមធម៌។

## ៣. យន្តការ និង ភារកិច្ច

យន្តការ ដែលទទួលខុសត្រូវក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក គឺ ៖

**៣.១. ក្រុមប្រឹក្សាស្រុក** មានភារកិច្ច ៖

- ចេញសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ដោយធានាឲ្យមានភាពគ្រប់ជ្រុងជ្រោយ និងឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដូចជា ស្ត្រី កុមារ ជនពិការ យុវជន និងជនងាយរងគ្រោះ។ល។
- ពិនិត្យ និងអនុម័តប្រតិទិនរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

- ចូលរួមក្នុងដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ពិនិត្យ និងអនុម័តលើសំណើកែតម្រូវកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកក្នុងករណីចាំបាច់
- តាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

៣.២. **គណៈអភិបាលស្រុក** មានភារកិច្ច ៖

- ដឹកនាំ និងសម្របសម្រួលការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ស្របតាមការណែនាំពីក្រុមប្រឹក្សាស្រុក ដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ ក្នុងដំណើរការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ដឹកនាំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្នាក់ស្រុក
- ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក មុនពេលក្រុមប្រឹក្សាស្រុកពិនិត្យ និងអនុម័ត
- ដាក់ជូនក្រុមប្រឹក្សាស្រុកពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

៣.៣. **ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគស្រុក** មានភារកិច្ច ៖

- រៀបចំសេចក្តីព្រាងសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ដឹកនាំ និងសម្របសម្រួលការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់នានាជាមួយបណ្តាភាគីពាក់ព័ន្ធ ក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក និងរៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្នាក់ស្រុក
- រៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- រៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

៣.៤. **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស** មានភារកិច្ច ៖

- ចូលរួមរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- សម្របសម្រួលរាល់ការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ពិនិត្យ និងជូនយោបល់ទៅក្រុមប្រឹក្សាស្រុក មុនធ្វើការអនុម័តលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

យន្តការទាំងបួនខាងលើ គឺជាយន្តការស្នូលក្នុងការចូលរួម និងទទួលខុសត្រូវផ្ទាល់លើការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។ ជាមួយគ្នានេះ ដើម្បីធានាឲ្យកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកមានគុណភាព នោះចាំបាច់ត្រូវមានយន្តការគាំទ្រ ដែលមាន ៖

**៣.៥. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក** មានភារកិច្ច ៖

- ចូលរួមផ្តល់ព័ត៌មាន និងការពារខ្លឹមសារការងារក្នុងដែនសមត្ថកិច្ចខ្លួននៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- សហការបំពេញការងារនានា តាមសំណូមពរពីក្រុមការងារកសាងផែនការស្រុក ដើម្បីកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

**៣.៦. មន្ទីរផែនការខេត្ត** មានភារកិច្ច ៖

- គាំទ្របច្ចេកទេសកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ដូចជា ការងារស្រង់ទិន្នន័យពីមូលដ្ឋានភូមិ ឃុំ ការងារចងក្រងកម្រងព័ត៌មានស្ថានភាពស្រុកប្រចាំឆ្នាំ ឯកសារពិន្ទុវិស័យ និងគាំទ្រការងាររៀបចំ និងសម្របសម្រួលក្នុងសិក្ខាសាលាសមាហរណកម្មនៅស្រុក។
- សហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត និងទីចាត់ការផែនការ និងវិនិយោគខេត្តក្នុងការបណ្តុះបណ្តាលអំពីបច្ចេកទេសកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ការប្រើប្រាស់ទិន្នន័យ និងបច្ចេកទេសតាមដាន និងវាយតម្លៃលទ្ធផលអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។
- សហការផ្តល់ការគាំទ្របច្ចេកទេសអំពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក និងការតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ដល់សមាជិកក្រុមប្រឹក្សាស្រុក និងបុគ្គលិកសំខាន់ៗរបស់ស្រុក តាមសំណើពីអ្នកពាក់ព័ន្ធ។

**៣.៧. ទីចាត់ការផែនការ និងវិនិយោគខេត្ត** មានភារកិច្ច ៖

- ផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាស្រុក ក្រុមការងារកសាងផែនការ និងអ្នកពាក់ព័ន្ធអំពីនីតិវិធីកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ដោយមានកិច្ចសហការជាមួយមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត មន្ទីរផែនការខេត្ត និងឬអង្គភាពជំនាញ ក្នុងករណីចាំបាច់។
- ជំរុញ និងគាំទ្រការប្រមូល និងរក្សាសៀវភៅកម្មវិធីវិនិយោគទុកជាឯកសារ
- ជួយក្រុមប្រឹក្សាស្រុក ក្នុងការរៀបចំ និងអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ការតាមដាន និងវាយតម្លៃអំពីលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

**៣.៨. ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់របស់រដ្ឋបាលស្រុក** មានភារកិច្ច ៖

- ជួយក្រុមប្រឹក្សា និងគណៈអភិបាលស្រុកក្នុងការដឹកនាំ និងសម្របសម្រួលការរៀបចំ ការកសាង ការពិនិត្យ អនុម័ត និងការតាមដាន វាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ជួយក្រុមការងារកសាងផែនការស្រុក ក្នុងការដឹកនាំ និងសម្របសម្រួលការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ចូលរួមក្នុងការវិភាគស្ថានភាពស្រុក
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

**៣.៩. ការិយាល័យផែនការស្រុក** មានភារកិច្ច ៖

- ជួយសម្របសម្រួល និងជំរុញអាជ្ញាធរភូមិ ឃុំ ក្នុងការស្រង់ទិន្នន័យមូលដ្ឋានភូមិ ឃុំ ស្រុក
- ជួយ ក្រុមការងារកសាងផែនការស្រុក ក្នុងការវិភាគពត៌មានស្ថានភាព និងពិន្ទុវិស័យភូមិ ឃុំ ស្រុក
- សហការជាមួយក្រុមការងារកសាងផែនការស្រុកក្នុងការរៀបចំបណ្ណាឧបករណ៏សម្រាប់ចូលរួមសិក្ខាសាលាសមាហរណកម្មនៅស្រុក។

**៣.១០. ការិយាល័យជំនាញ និងអង្គភាពនានានៅថ្នាក់ស្រុក** មានភារកិច្ច ៖

- ចូលរួម និងផ្តល់ព័ត៌មានជាធាតុចូលដល់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ចូលរួមក្នុងការវិភាគស្ថានភាពស្រុក
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

**៣.១១. មេឃុំ** មានភារកិច្ច ៖

- ចូលរួម និងផ្តល់ព័ត៌មានជាធាតុចូលពាក់ព័ន្ធនឹងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ចូលរួមសិក្ខាសាលាសមាហរណកម្មផែនការនៅស្រុក(DIW)។

**៣.១២. អង្គការសង្គមស៊ីវិល វិស័យឯកជន និងក្រុមពាក់ព័ន្ធនានា**

ក្នុងដំណើររៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក អង្គការសង្គមស៊ីវិល វិស័យឯកជន ក្រុមយុវជន និងក្រុមពាក់ព័ន្ធនានា ក្នុងស្រុកគប្បីត្រូវបានចូលរួមក្នុងការពិភាក្សា ផ្តល់ព័ត៌មានជាធាតុចូលនានាដែលពាក់ព័ន្ធនឹងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

# ផ្នែកទី២
# ទម្រង់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

**១ .គ្របមុខ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កម្មវិធីវិនិយោគបីឆ្នាំរំកិល

**២០....២០ - ....**

**ស្រុក..........ខេត្ត............**

បានទទួលការអនុម័តពីក្រុមប្រឹក្សាស្រុក
ក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញ លើកទី ថ្ងៃទី ខែ ឆ្នាំ២០...

## ២. មាតិកាសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

**សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក**

**អារម្ភកថា**

**សេចក្តីផ្តើម**

**ផែនទី**

**ជំពូកទី១ ÷ ស្ថានភាពទូទៅ និងបញ្ហាប្រឈម**

១.១.សេចក្តីសង្ខេបទិន្នន័យចម្បងរបស់ស្រុក

១.២.ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ៖

- ផ្នែកសេដ្ឋកិច្ច
- ផ្នែកសង្គមកិច្ច
- ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ផ្នែករដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

**ជំពូកទី២ ÷ គម្រោង សកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក**

២.១. តារាងសង្ខេបប្រភពមូលនិធិ

២.២. តារាងគម្រោង សកម្មភាពកំពុងដំណើរការ

២.៣. តារាងគម្រោង សកម្មភាពវិនិយោគមានថវិកាគាំទ្រ

២.៤. តារាងគម្រោង សកម្មភាពអាទិភាពមិនទាន់មានថវិកាគាំទ្រ

២.៥. តារាងកម្មវិធីប្រតិបត្តិការសេវារដ្ឋបាល

២.៦. តារាងការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា

២.៧. តារាងគម្រោង សកម្មភាពរបស់ក្រសួង ស្ថាប័នកំពុងដំណើរការ

**ជំពូកទី៣ ÷ ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក**

៣.១. ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ

៣.២. ការបែងចែកភារកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងការតាមដាន និងវាយតម្លៃ

៣.៣. តារាងតាមដាន និងវាយតម្លៃ

**ឧបសម្ព័ន្ធ**

## ៣. សេចក្តីពន្យល់

## បណ្តាសមាសធាតុនៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

### សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

បន្ទាប់ពីទំព័រក្របសៀវភៅ គឺសេចក្តីសម្រេច។ សេចក្តីសម្រេច គឺជាលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាស្រុក ក្នុងការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។ ខ្លឹមសារសំខាន់ក្នុងសេចក្តីសម្រេចមាន ការចូលជាធរមាននូវកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ការណែនាំដល់គណៈអភិបាលស្រុកឲ្យធ្វើការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។ សេចក្តីសម្រេចនេះចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាស្រុក ។

### អារម្ភកថា

អារម្ភកថា គឺជាអត្ថបទបង្ហាញពីសារៈប្រយោជន៍នៃកម្មវិធីវិនិយោគបីឆ្នាំរំកិល ការថ្លែងអំណរគុណចំពោះ អ្នកដែលបានចូលរួមរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល និងសេចក្តីសង្ឃឹមថានឹងទទួលបានការគាំទ្រពីអ្នកពាក់ព័ន្ធ (អារម្ភកថាមិនគួរសរសេរវែងពេក ត្រឹមមួយទំព័រគឺជាការប្រសើរ)។ អារម្ភកថា ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាស្រុក។

### សេចក្តីផ្តើម

សេចក្តីផ្តើម ត្រូវសរសេរពីវឌ្ឍនភាពនៅក្នុងស្រុក និងមូលហេតុដែលនាំឲ្យមានការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ព្រមទាំងគោលបំណង និងសង្ខេបពីដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(សេចក្តីផ្តើមគួរសរសេរខ្លីដែរ)។

### ផែនទី

ជាផែនទីស្រុក ដែលបង្ហាញពីលក្ខណៈភូមិសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និងទីតាំងរដ្ឋបាលក្នុងស្រុក។ ផែនទីនេះរៀបចំលើក្រដាសទំហំA3 និងប្រើនិមិត្តសញ្ញាតាងឱ្យវត្ថុកំពុងមានក្នុងស្រុក ដូចជា៖ និមិត្តសញ្ញានៃប្រព័ន្ធផ្លូវថ្នល់ ស្ពាន លូរំដោះទឹក ប្រព័ន្ធប្រឡាយទឹក ទីតាំងរដ្ឋបាល ទីតាំងសាលារៀន ទីតាំងផ្តល់សេវាសុខភាពសាធារណៈ ទីតាំងសាសនា វាលស្រែ ធនធានធម្មជាតិ ។ល។

## ជំពូកទី១ ÷ ស្ថានភាពទូទៅ និងបញ្ហាប្រឈមក្នុងស្រុក

### ១.១. សេចក្តីសង្ខេបទិន្នន័យចម្បងរបស់ស្រុក

សេចក្តីសង្ខេបទិន្នន័យចម្បងរបស់ស្រុកត្រូវបានបង្ហាញតាមបែបវិភាគក្នុងតារាងខាងក្រោម៖

**តារាងសង្ខេបទិន្នន័យចម្បងរបស់ស្រុក**

| ល.រ | បរិយាយ | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... |
|---|---|---|---|---|---|---|
| **ព័ត៌មានទូទៅ** | | | | | | |
| ១ | ផ្ទៃដីស្រុក (គ.ម$^{២}$ ) | | | | | |
| ២ | ចំនួនឃុំ | | | | | |

| ល.រ | បរិយាយ | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... |
|---|---|---|---|---|---|---|
| ៣ | ចំនួនភូមិ | | | | | |
| ៤ | ចំនួនគ្រួសារ | | | | | |
| ៥ | % មេគ្រួសារជាស្ត្រី | | | | | |
| ៦ | ចំនួនប្រជាជនសរុប | | | | | |
| ៧ | ចំនួនស្រី | | | | | |
| ៨ | ចំនួនប្រុស | | | | | |
| ៩ | % អ្នកមានអាយុពី០-១៧ឆ្នាំ | | | | | |
| ១០ | % អ្នកមានអាយុពី១៨-៦០ឆ្នាំ | | | | | |
| ១១ | % អ្នកមានអាយុពី៦១ឆ្នាំឡើង | | | | | |
| ១២ | កំណើនប្រជាជនប្រចាំឆ្នាំ (%) | | | | | |
| ១៣ | អត្រាភាពក្រីក្រ (%) | | | | | |
| ១៤ | % អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម | | | | | |
| ១៥ | % អ្នកមានមុខរបរចម្បងផ្នែកសិប្បកម្ម | | | | | |
| ១៦ | % អ្នកមានមុខរបរចម្បងផ្នែកសេវាកម្ម | | | | | |
| ១៧ | % មនុស្សទៅរកការងារធ្វើនៅក្នុងប្រទេស | | | | | |
| ១៨ | % មនុស្សទៅរកការងារធ្វើនៅក្រៅប្រទេស | | | | | |
| ១៩ | % ខ្ទង់ផ្ទះមានអគ្គិសនីប្រើប្រាស់ | | | | | |
| **អប់រំ** | | | | | | |
| ២០ | % កុមារអាយុ៣-៥ឆ្នាំបានចូលរៀន | | | | | |
| ២១ | % កុមារអាយុ៦ឆ្នាំបានចូលរៀន | | | | | |
| ២២ | % កុមារអាយុ៦-១១ឆ្នាំបានចូលរៀន | | | | | |
| ២៣ | % កុមារអាយុ១២-១៤ឆ្នាំនៅរៀន | | | | | |
| ២៤ | % អ្នកចេះអក្សរអាយុ១៥-១៧ឆ្នាំ | | | | | |
| ២៥ | % អ្នកចេះអក្សរអាយុ១៨-៤៥ឆ្នាំ | | | | | |
| **សុខភាព** | | | | | | |
| ២៦ | ចំនួនមណ្ឌលសុខភាព | | | | | |
| ២៧ | % ស្ត្រីសម្រាលកូនដោយឆ្មបពេទ្យ | | | | | |
| ២៨ | អត្រាស្លាប់របស់មាតាក្រោយពេលសម្រាល(០-១ខែ) ក្នុង១ពាន់កំណើត | | | | | |
| ២៩ | អត្រាស្លាប់របស់ទារកក្រោយពេលកើត(០-១ខែ)ក្នុង១ពាន់កំណើត | | | | | |
| ៣០ | % កុមារអាយុពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | | | | | |
| ៣១ | ចំនួនគ្រួសារមានសមាជិកកើតជំងឺអេដស៍ | | | | | |
| **ភាពងាយរងគ្រោះ** | | | | | | |
| ៣២ | ចំនួនជនពិការ | | | | | |
| ៣៣ | % ជនពិការអាយុ១៨ឆ្នាំឡើងមិនអាចរកចំណូលបាន | | | | | |
| ៣៤ | ចំនួនកុមារកំព្រាឪពុកម្តាយស្លាប់ដោយជំងឺអេដស៍ | | | | | |
| ៣៥ | ចំនួនចាស់ជរាគ្មានទីពឹង(អាយុ៦១ឆ្នាំឡើង) | | | | | |
| **ធនធានធម្មជាតិ បរិស្ថាន និងការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ** | | | | | | |
| ៣៦ | ចំនួនគ្រួសាររងគ្រោះដោយខ្យល់កន្ត្រាក់ | | | | | |
| ៣៧ | ចំនួនគ្រួសាររងគ្រោះដោយទឹកជំនន់ | | | | | |
| ៣៨ | ចំនួនគ្រួសាររងគ្រោះដោយរាំងស្ងួត | | | | | |
| ៣៩ | % គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | | | | | |
| ៤០ | % គ្រួសារមានទឹកស្អាតប្រើប្រាស់ | | | | | |
| ក្នុងនោះ: | % គ្រួសារមានទឹកម៉ាស៊ីនប្រើប្រាស់ | | | | | |
| | % គ្រួសារមានទឹកអណ្តូងស្នប់ឬអណ្តូងចំរុះ | | | | | |
| | % គ្រួសារប្រើទឹកអណ្តូងជីកមានការការពារ | | | | | |
| | % គ្រួសារប្រើទឹកភ្លៀងមានការការពារ | | | | | |
| ៤១ | % គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | | | | | |

| ល.រ | បរិយាយ | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... | ឆ្នាំ... |
|---|---|---|---|---|---|---|
| **រដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | | |
| ៤២ | % កុមារបានចុះសំបុត្រកំណើត (០-៣០ថ្ងៃ) | | | | | |
| ៤៣ | ចំនួនគ្រួសារមានអំពើហិង្សាក្នុងគ្រួសារ | | | | | |
| ៤៤ | ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ | | | | | |
| ៤៥ | ចំនួនអ្នកស្លាប់ដោយអំពើហិង្សានានា | | | | | |
| ៤៦ | ចំនួនគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន | | | | | |

## ១.២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមក្នុងស្រុក

ផ្នែកនេះ ត្រូវអធិប្បាយនិងសរសេរតាមបែបវិភាគអំពីបច្ចុប្បន្នភាពនៃស្ថានភាពនានា និងកំណត់យកដំណោះស្រាយបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងផែនការអភិវឌ្ឍន៍ស្រុក។ ការអធិប្បាយ និងសរសេរត្រូវធ្វើតាមលំដាប់លំដោយ ដោយផ្តើមពីស្ថានភាពសេដ្ឋកិច្ច ទៅស្ថានភាពសង្គមកិច្ច ស្ថានភាពប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន (ការគ្រប់គ្រងគ្រោះមហន្តរាយ ការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ...) រហូតដល់ស្ថានភាពគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។ ក្រុមការងារកសាងផែនការស្រុក សរសេរស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមរបស់ស្រុក ដោយផ្អែកលើព័ត៌មានស្តីពីលទ្ធផលនៃការវិភាគពិន្ទុវិស័យ និងស្ថានភាពឃុំ ស្រុក។

## ជំពូកទី២ ÷ គម្រោង សកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

ផ្តើមដោយអត្ថបទដែលបរិយាយសង្ខេបពីតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍនៅឆ្នាំខាងមុខ។ បន្ទាប់មក ត្រូវរៀបចំបណ្តាតារាងគម្រោង សកម្មភាពវិនិយោគបីឆ្នាំរំកិលរបស់ស្រុក ដែលមានជាអាទិ៍ ៖

**តារាង២.១. សង្ខេបប្រភពមូលនិធិឆ្នាំ..........**

| ល.រ | ស្ថាប័ន | ចំនួនគម្រោង | សរុបតម្លៃគម្រោង (លានរៀល) | ប្រភពមូលនិធិ | ចំនួនគម្រោង | តម្លៃគម្រោង (លានរៀល) |
|---|---|---|---|---|---|---|
| ១ | សាលាស្រុក | | | ស្រុក | | |
| | | | | ដៃគូអភិ. | | |
| | | | | សប្បុរសជន | | |
| ២ | ការគាំទ្រតាមបណ្តាមន្ទីរ អង្គភាព/ការិយាល័យជំនាញ | | | | | |
| ២.១ | មន្ទីរ/ការិយាល័យ... | | | មន្ទីរ/ការិ. | | |
| | | | | ដៃគូអភិ. | | |
| ២.២ | មន្ទីរ/ការិយាល័យ... | | | មន្ទីរ/ការិ. | | |
| | | | | ដៃគូអភិ. | | |
| ... | ... | | | | | |
| | | | | | | |
| សរុបមន្ទីរអង្គភាព | | | | មន្ទីរ | | |
| | | | | ដៃគូអភិ. | | |
| ៣ | ការគាំទ្រពីអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធ | | | | | |
| ៣.១. | អង្គការ.. | | | | | |
| ៣.២. | អង្គការ.. | | | | | |
| ... | ... | | | | | |
| សរុបអង្គការ ដៃគូ... | | | | | | |
| **សរុបរួម** (1+2+3) | | | | | | |

## តារាង២.២. គម្រោង សកម្មភាពកំពុងដំណើរការ

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតប គោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេល អនុវត្ត | តម្លៃ | ប្រភព មូលនិធិ | កម្រិតទុនវិនិយោគ (លានរៀល) | | | | អង្គភាព អនុវត្ត | កំណត់ សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | ២... | ២... | ២... | សរុប | | |
| **ក.គម្រោង សកម្មភាពរបស់រដ្ឋបាលស្រុក** | | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| **ខ.គម្រោង សកម្មភាពរបស់ការិយាល័យ អង្គភាព និងអ្នកពាក់ព័ន្ធ** | | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |
| | | | | | | | | | | | | | | |

**កំណត់សម្គាល់ ៖** ជាតារាងដែលបង្ហាញពីប្រភេទគម្រោង សកម្មភាពកំពុងអនុវត្តក្នុងឆ្នាំរៀបចំកម្មវិធីវិនិយោគ ឬឆ្នាំសារពើពន្ធថវិកា ហើយនឹងត្រូវបន្តអនុវត្តនៅឆ្នាំមុខទៀត។

## តារាង២.៣. គម្រោង សកម្មភាពវិនិយោគស្រុកមានថវិកាគាំទ្រ

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតបគោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃ | ប្រភពមូលនិធិ | កម្រិតទុនវិនិយោគ (លានរៀល) | | | | អង្គភាពអនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | | ២... | ២... | ២... | សរុប | |
| **ក.គម្រោង សកម្មភាពរបស់រដ្ឋបាលស្រុក** | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| **ខ.គម្រោង សកម្មភាពរបស់ការិយាល័យ អង្គភាព និងអ្នកពាក់ព័ន្ធ** | | | | | | | | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

**កំណត់សម្គាល់ ៖** ជាតារាងដែលបង្ហាញពីប្រភេទគម្រោង សកម្មភាពដែលប្រើប្រាស់មូលនិធិស្រុក និងប្រើប្រាស់មូលនិធិដែលទទួលបានសន្យាគាំទ្រពីមន្ទីរ អង្គភាព អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។

**តារាង២.៤. គម្រោង សកម្មភាពអាទិភាពស្រុកដែលមិនទាន់មានថវិកាគាំទ្រ**

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតប គោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេល អនុវត្ត | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន (លានរៀល) | អង្គភាពស្នើ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

**តារាង២.៥. កម្មវិធីប្រតិបត្តិការសេវារដ្ឋបាល ឆ្នាំ........**

| ល.រ | ប្រភេទសេវា | លទ្ធផល | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|
| | | បរិមាណ | ឯកតា | | |
| ក. កម្មវិធីប្រតបត្តិការសេវារបស់រដ្ឋបាលស្រុក | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ខ. កម្មវិធីប្រតបត្តិការសេវារបស់ការិយាល័យជំនាញ | | | | | |
| | | | | | |
| | | | | | |
| | | | | | |

**តារាង២.៦. ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលស្រុក ឆ្នាំ.....**

| ល.រ | ប្រភេទលិខិតបទដ្ឋាន | លទ្ធផល | | ផ្សេងៗ |
|---|---|---|---|---|
| | | បរិមាណ | ឯកតា | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

### តារាង២.៧. គម្រោង សកម្មភាពរបស់ក្រសួង ស្ថាប័ន កំពុងអនុវត្តក្នុងដែនដីស្រុក

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ទីតាំង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃ | ប្រភពមូលនិធិ | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | |
| ១. ក្រសួង... | | | | | | | | |
| ១ | | | | | | | | |
| ២ | | | | | | | | |
| ២. ក្រសួង... | | | | | | | | |
| ១ | | | | | | | | |
| ២ | | | | | | | | |
| | | | | | | | | |

## ជំពូកទី៣ ÷ ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល គឺជាសកម្មភាពផ្តោតលើការសន្និដ្ឋានពីស្ថានភាព និងលទ្ធផលនៃការអនុវត្ត ៖

- គម្រោង សកម្មភាពកំពុងដំណើរការ
- គម្រោង សកម្មភាពមានថវិកាគាំទ្រ
- គម្រោង សកម្មភាពអាទិភាពដែលមិនទាន់មានថវិកាគាំទ្រ
- តើមានការគាំទ្រគម្រោង សកម្មភាពថ្មីបន្ថែមក្រៅពីគម្រោង សកម្មភាពអាទិភាពមិនទាន់មានការសន្យាគាំទ្រ ឬទេ?)។ល។
- កម្មវិធីប្រតិបត្តិការសេវារដ្ឋបាលរបស់រដ្ឋបាលស្រុក និងរបស់ការិយាល័យជំនាញ
- ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា។

### តារាងតាមដានការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

| លរ. | ឈ្មោះគម្រោង | គ្រោង/ ជាក់ស្តែង | លទ្ធផល | | រយៈ ពេល អនុវត្ត | តម្លៃ គម្រោង | អង្គភាព អនុវត្ត | % នៃការ សម្រេច | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | | |
| **១.គម្រោងវិនិយោគរបស់រដ្ឋបាលស្រុក** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **២. កម្មវិធីប្រតិបត្តិការសេវារដ្ឋបាលរបស់រដ្ឋបាលស្រុក** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **៣. ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលស្រុក** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |

## តារាងតាមដានការអនុវត្ត
## គម្រោងវិនិយោគ និងការប្រតិបត្តិការសេវារបស់ការិយាល័យជំនាញ

| លរ. | ឈ្មោះគម្រោង | គ្រោង/ជាក់ស្តែង | លទ្ធផល | | រយៈពេលអនុវត្ត | តម្លៃគម្រោង | អង្គភាពអនុវត្ត | % នៃការសម្រេច | ម្ចាស់គម្រោង |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | | |
| **១.គម្រោងវិនិយោគរបស់ការិយាល័យជំនាញ** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **២. កម្មវិធីប្រតិបត្តិការសេវារដ្ឋបាល របស់ការិយាល័យជំនាញ** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |

**ឧបសម្ព័ន្ធ ÷**

- ក្នុងការរៀបចំផ្នែកឧបសម្ព័ន្ធនៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ក្រុមការងារកសាងផែនការស្រុកអាចពិចារណាដាក់បញ្ចូលនូវតារាង ឬព័ត៌មានពាក់ព័ន្ធនានា តាមការចាំបាច់។

# ផ្នែកទី៣

# វិធីសាស្ត្ររៀបចំ និង

# កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

# ជំហានទី១
# ការប្រមូលព័ត៌មានស្តីពីតម្រូវការ
# របស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

**គោលបំណង**

គោលបំណងនៃជំហានទី១នេះ គឺប្រមូលតម្រូវការអភិវឌ្ឍន៍នានារបស់ស្រុក ដើម្បីធ្វើជាធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាខេត្ត គម្រោងថវិកាប្រចាំឆ្នាំខេត្ត និងសម្រាប់ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

**លទ្ធផលរំពឹងទុក**

បញ្ជីតម្រូវការគម្រោង សកម្មភាពទាំងផ្នែករូបវន្ត អរូបវន្ត និងសេវារដ្ឋបាលនានាដែលស្រុកមានបំណងចង់ធ្វើនៅឆ្នាំខាងមុខ សម្រាប់ធ្វើជាធាតុចូលក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងរៀបចំផែនការយុទ្ធសាស្ត្រថវិកាខេត្តបានផ្ញើដល់រដ្ឋបាលខេត្ត។

**ដំណើរការ**

សកម្មភាពសំខាន់ៗ ដែលត្រូវអនុវត្តក្នុងជំហានទី១នេះ រួមមាន ៖

១.១. ប្រជុំណែនាំអំពីការប្រមូលតម្រូវការអាទិភាព

១.២. ប្រជុំបូកសរុប និងរៀបបញ្ជីគម្រោង និងសកម្មភាពអាទិភាព

## ១.១. ប្រជុំណែនាំពីការប្រមូលតម្រូវការអាទិភាព

បន្ទាប់ពីបានចូលរួមកិច្ចប្រជុំណែនាំនៅខេត្ត ក្រុមការងារកសាងផែនការស្រុក រៀបចំកិច្ចប្រជុំណែនាំបន្ត ស្តីពីការប្រមូលតម្រូវការអាទិភាពសម្រាប់ការអភិវឌ្ឍន៍របស់មូលដ្ឋានដល់អ្នកពាក់ព័ន្ធនៅថ្នាក់ស្រុក។

**សមាសភាពចូលរួម**

- គណៈអភិបាលស្រុក
- តំណាងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក
- ការិយាល័យ អង្គភាពនានាជុំវិញស្រុក
- ក្រុមការងារកសាងផែនការស្រុក
- ប្រធានការិយាល័យនានារបស់រដ្ឋបាលស្រុក
- មេឃុំ
- អង្គការ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។ល។

**កិច្ចដំណើរការក្នុងអង្គប្រជុំ**

អភិបាលស្រុក ឬតំណាង បញ្ជាក់ពីគោលបំណងនៃការប្រជុំណែនាំអំពីការប្រមូលតម្រូវការអភិវឌ្ឍន៍ និងសំណូមពរនានា។ ដោយមានការអនុញ្ញាតពីប្រធានអង្គប្រជុំ តំណាងក្រុមការងារកសាងផែនការស្រុកបង្ហាញអំពី ៖

- ព័ត៌មានស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ពិន្ទុវិស័យ និងអត្រាភាពក្រីក្រ... របស់ស្រុក
- នីតិវិធី និងដំណើរការនៃការកំណត់យកតម្រូវការអាទិភាពនៅមូលដ្ឋាន ដែលរួមមាន ៖

- ការវិភាគស្ថានភាព (ឧបសម្ព័ន្ធទី៣ និងទី៨នៃផ្នែកទី៤)
- លក្ខណៈវិនិច្ឆ័យនៃគម្រោងដែលត្រូវស្នើដើម្បីដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគស្រុក (ចំណុច "ខ" នៃទម្រង់ទី១ គឺជាគម្រោង ឬសកម្មភាពដែល ៖
  + ឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ស្រុក
  + ស្ថិតនៅក្នុងដែនសមត្ថកិច្ចស្រុក
  + គម្រោងដែលមានលក្ខណៈអន្តរឃុំ
- វិធីសាស្ត្រចាត់អាទិភាព និងជ្រើសរើសគម្រោងនានា (ឧបសម្ព័ន្ធទី២ក្នុងផ្នែកទី៤)

• របៀបបំពេញទម្រង់ទី១

ពេលបង្ហាញទម្រង់ និងរបៀបបំពេញទម្រង់ ក្រុមការងារកសាងផែនការស្រុក ត្រូវបញ្ជាក់បន្ថែមអំពីចំនួនអតិបរមានៃគម្រោង សកម្មភាពស្នើ និងកាលបរិច្ឆេទនៃការបញ្ជូនតារាងតម្រូវការគម្រោង សកម្មភាពអាទិភាពមកឲ្យក្រុមការងារកសាងផែនការស្រុកវិញ។

បន្ទាប់ពីចូលរួមកិច្ចប្រជុំណែនាំនៅស្រុក រដ្ឋបាលស្រុក រដ្ឋបាលឃុំ ការិយាល័យ អង្គភាព អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាក្នុងស្រុក ត្រូវធ្វើការវិភាគស្ថានភាព និងកំណត់យកតម្រូវការអភិវឌ្ឍន៍មូលដ្ឋាន និងវិស័យខ្លួនសម្រាប់បំពេញតារាងទម្រង់ទី១ និងបញ្ជូនមកក្រុមការងារកសាងផែនការស្រុកឲ្យបានទាន់ពេលកំណត់។

### ១.២. ប្រជុំបូកសរុប និងចងក្រងបញ្ជីគម្រោង និងសកម្មភាពមានតម្រូវការជាអាទិភាព

- បន្ទាប់ពីទទួលបានទម្រង់ទី១ ដែលបំពេញដោយរដ្ឋបាលឃុំ ការិយាល័យ និងអង្គភាពនានាក្នុងស្រុក ក្រុមការងារកសាងផែនការស្រុក ត្រូវបូកសរុបតម្រូវការគម្រោង សកម្មភាពជាអាទិភាពទាំងនោះតាមលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់ដោយមានការចូលរួមរបស់ តំណាងការិយាល័យ អង្គភាពនានាក្នុងស្រុក មេឃុំ និងអ្នកពាក់ព័ន្ធតាមការចាំបាច់។
- ពេលប្រជុំបូកសរុបគម្រោង សកម្មភាពមានតម្រូវការអាទិភាព ក្រុមការងារកសាងផែនការស្រុក ត្រូវចៀសវៀងការបូកសរុបស្ទួន ដោយត្រូវសួរបញ្ជាក់ទៅអ្នកពាក់ព័ន្ធនឹងគម្រោងសកម្មភាពណាដែលសរសេរ ឬមានន័យមិនច្បាស់ ឈ្មោះមិនសមស្រប។
- ក្រុមការងារកសាងផែនការស្រុកត្រូវពិនិត្យគម្រោងសំណើទាំងអស់ដែលបានទទួលដើម្បីរៀបចំតារាង១.១.ក ដោយត្រូវកំណត់តាមកំដាប់លំដោយដូចខាងក្រោម ៖

  **ក.** រៀបចំតម្រូវការគម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគស្រុកដោយពិនិត្យលើ ៖
  - សំណើគម្រោង (ចំណុច"ខ"នៃទម្រង់ទី១) ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដូចបានកំណត់
  - គម្រោងអាទិភាពកាលពីឆ្នាំកន្លងទៅ ហើយមិនបានអនុវត្ត ថាតើគម្រោងទាំងនោះនៅតែជាតម្រូវការអាទិភាពឬទេ? ប្រសិនបើនៅតែជាតម្រូវការអាទិភាព ក្រុមការងារកសាងផែនការស្រុកត្រូវស្រង់គម្រោងទាំងនោះចូលក្នុងផ្នែក "ក" នៃតារាង១.១.ក
  - គម្រោង ឬសកម្មភាពនានាដើម្បីអនុវត្តមុខងារជាកាតព្វកិច្ច និងឬមូលនិធិមានភ្ជាប់លក្ខខណ្ឌនានាដែលរដ្ឋបាលស្រុកបានទទួល
  - តម្រូវការដាក់ស្តែងបន្ថែមទៀត ដើម្បីឆ្លើយតបគោលដៅអភិវឌ្ឍន៍នានា ដែលបានកំណត់

**ខ.** តម្រូវការគម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគខេត្ត ដោយ ៖
- ពិនិត្យមើលគម្រោង សកម្មភាពនានាដែលបានស្នើបញ្ចូលក្នុងកម្មវិធីវិនិយោគស្រុក ហើយដែលសមស្របនឹងតួនាទី សមត្ថភាព លទ្ធភាពអនុវត្តរបស់ខេត្ត
- ក្រុមការងារកសាងផែនការស្រុកត្រូវស្រង់គម្រោងទាំងនោះចូលក្នុងតារាង១.១.ក ចំណុច "ខ" គម្រោង សកម្មភាពសម្រាប់កម្មវិធីវិនិយោគខេត្ត
- ពិនិត្យមើលព័ត៌មាននៅក្នុងទម្រង់ទី១ ចំណុច "ក" ដែលបានទទួលពីរដ្ឋបាលឃុំ

**គ.** ចំពោះគម្រោង សកម្មភាពសមស្របតាមតួនាទី សមត្ថភាព លទ្ធភាពអនុវត្តរបស់ឃុំ ក្រុមការងារកសាងផែនការស្រុក ត្រូវស្រងគម្រោងទាំងនោះ ដាក់ក្នុងតារាង១.១.ក ចំណុច "គ" គម្រោង សកម្មភាពសម្រាប់កម្មវិធីវិនិយោគឃុំ។

- ក្រុមការងារកសាងផែនការស្រុក ត្រូវជូនដំណឹងទៅ គ.ផ.ថ នៃឃុំនីមួយៗអំពីការកែសម្រួល ឬការផ្លាស់ប្តូរគម្រោងក្នុងចំណុច "គ" ខាងលើ។

តារាង១.១.ក ៖ តម្រូវការគម្រោង សកម្មភាពអាទិភាពទូទាំងស្រុក

| ល.រ | ឈ្មោះម្រោង សកម្មភាព | ឆ្លើយតប គោលដៅ | ទីតាំង | លទ្ធផល | | រយៈពេល | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| ក ៖ តម្រូវការគម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគស្រុក | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ខ ៖ តម្រូវការគម្រោងដែលស្រុក ស្នើសុំបញ្ចូលទៅក្នុងកម្មវិធីវិនិយោគខេត្ត | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| គ ៖ គម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគឃុំ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

បន្ទាប់ពីរៀបចំបញ្ចប់តារាងខាងលើ ក្រុមការងារកសាងផែនការស្រុកត្រូវរៀបចំបំពេញទម្រង់ទី១ របស់ខេត្ត តាមការណែនាំរបស់ក្រុមការងារកសាងផែនការខេត្ត ហើយត្រូវចាត់ចែងបញ្ជូនទម្រង់ទី១នេះ ទៅក្រុមការងារកសាងផែនការខេត្ត តាមកាលបរិច្ឆេទដែលបានកំណត់។

## ជំហានទី២

## ការរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

**គោលបំណង**

គោលបំណងនៃជំហានទី២នេះ គឺការរៀបចំ និងចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកដោយមានភាពជាក់លាក់ មានការចូលរួម អាចអនុវត្តបាន និងមានសង្គតិភាពជាមួយនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ស្រុក។

**លទ្ធផលរំពឹងទុក**

សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ត្រូវបានបញ្ចប់ និងដាក់ជូនក្រុមប្រឹក្សាស្រុកពិនិត្យអនុម័ត។

**សកម្មភាពអនុវត្ត**

ក្នុងជំហានទី២នេះ សកម្មភាពសំខាន់ដែលត្រូវអនុវត្តមាន ៖

២.១. កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

២.២. ចូលរួមវេទិកាពិគ្រោះយោបល់ក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅខេត្ត

២.៣. រៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅស្រុក

២.៤. ចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

២.៥. ការរៀបចំតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ

២.៦. ការពិនិត្យ និងផ្តល់យោបល់

### ២.១. ប្រជុំផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

**គោលបំណង**

គោលបំណងនៃកិច្ចប្រជុំនេះ គឺឲ្យអ្នកពាក់ព័ន្ធបានយល់ពីខ្លឹមសារនៃសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក លិខិតបទដ្ឋាននានា កញ្ចប់ថវិកាប្រចាំឆ្នាំ សារៈសំខាន់នៃការចូលរួម និងចូលរួមកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

**លទ្ធផលរំពឹងទុក**

លទ្ធផលរំពឹងទុកពីសកម្មភាពនេះ មាន ៖

- គ្រប់ភាគីពាក់ព័ន្ធយល់ដឹងពីគោលបំណងនៃការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- គ្រប់ភាគីពាក់ព័ន្ធទទួលបានការណែនាំពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកដោយបានយល់ និងចេះបំពេញបណ្តាតារាងចាំបាច់ ដូចជា ៖
  - តារាងគម្រោង សកម្មភាពមានថវិកាគាំទ្រ
  - តារាងគម្រោង សកម្មភាពកំពុងដំណើរការ

- តារាងគម្រោង សកម្មភាពមិនមានថវិកាគាំទ្រ
- តារាងគម្រោង សកម្មភាពរបស់ក្រសួង ស្ថាប័នកំពុងដំណើរការក្នុងដែនដីស្រុក
- តារាងគម្រោង សកម្មភាពរបស់អង្គការជាតិ អន្តរជាតិ និងវិស័យឯកជនកំពុងដំណើរការក្នុងដែនដីស្រុក
- តារាងគម្រោង សកម្មភាពវិនិយោគដែលបានបញ្ចប់។ល។

**ការងារត្រូវអនុវត្ត**

**ក). មុនកិច្ចប្រជុំផ្សព្វផ្សាយ**

សកម្មភាពដែលត្រូវអនុវត្តមុនកិច្ចប្រជុំផ្សព្វផ្សាយ រួមមាន ៖

- ក្រុមការងារកសាងផែនការស្រុក ត្រូវសុំកិច្ចសហការ និងគាំទ្រពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសស្រុកធ្វើការតាក់តែងសេចក្តីព្រាងសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក (ឧបសម្ព័ន្ធទី១នៃផ្នែកទី៤) ជូនអភិបាលស្រុកពិនិត្យ និងយោបល់ រួចដាក់ជូនក្រុមប្រឹក្សាស្រុកពិនិត្យ និងអនុម័ត។ សេចក្តីណែនាំនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាស្រុក។ ខ្លឹមសារនៃសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក មាន ៖
  - ការវាយតម្លៃលើស្ថានភាពទូទៅរបស់ស្រុក
  - ទិសដៅអភិវឌ្ឍន៍ចម្បងនានារបស់ស្រុកសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកខាងមុខ
  - វិធីសាស្ត្រ និងតួនាទីរបស់អ្នក ឬអង្គភាពពាក់ព័ន្ធក្នុងដំណើរប្រព្រឹត្តទៅនៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
  - ប្រតិទិនការងារ

> **បញ្ជាក់ ៖** ក្នុងការវាយតម្លៃលើស្ថានភាពទូទៅរបស់ស្រុក ក្រុមការងារកសាងផែនការស្រុក ត្រូវធ្វើការវិភាគទៅលើ ទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច និងស្ថានភាពបច្ចុប្បន្ន ក៏ដូចជាបញ្ហាប្រឈមរបស់ស្រុក។ សម្រាប់កម្មវិធីវិនិយោគបីឆ្នាំ រំកិលលើកទី១នៃអាណត្តិក្រុមប្រឹក្សា ការរៀបចំខ្លឹមសារស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ត្រូវផ្អែកតាមលទ្ធផលនៃការ វិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ស្រុក។ សម្រាប់ឆ្នាំបន្តបន្ទាប់ ការរៀបចំ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពដោយផ្អែកលើការប្រែប្រួលសំខាន់ៗ ដែលកើតមានឡើងក្រោយពីផែនការអភិវឌ្ឍន៍ស្រុក ត្រូវបានដាក់ឲ្យប្រើប្រាស់។ ត្រូវប្រើប្រាស់ឯកសារព័ត៌មានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ឯកសារពិន្ទុវិស័យ ឯកសាររបស់ការិយាល័យ អង្គភាពជំនាញក្នុងស្រុក និងឯកសារពាក់ព័ន្ធដ៏ទៃទៀតក្នុងការរៀបចំខ្លឹមសារស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចរបស់ស្រុក។

បន្ទាប់ពីសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកបានចូលជាធរមាន ក្រុមការងារកសាងផែនការស្រុក ត្រូវសុំគោលការណ៍ពីគណៈអភិបាលស្រុករៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

មុនពេលរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ក្រុមការងារកសាងផែនការស្រុក ត្រូវរៀបចំ ៖

- បញ្ជីឈ្មោះអ្នកត្រូវអញ្ជើញចូលរួមកិច្ចប្រជុំ
- របៀបវារៈនៃកិច្ចប្រជុំ
- ថតចម្លងសេចក្តីណែនាំ និងទម្រង់តារាងនានាដែលត្រូវបំពេញ (ដូចមានទម្រង់គំរូក្នុងផ្នែកទី៤នៃឯកសារណែនាំបច្ចេកទេសនេះ) សម្រាប់ចែកជូនអ្នកចូលរួមប្រជុំ
- រៀបចំឧបករណ៍សម្រាប់បង្ហាញពន្យល់ពីខ្លឹមសារនៃសេចក្តីណែនាំ និងឯកសារពាក់ព័ន្ធនានា
- កំណត់កាលបរិច្ឆេទនៃការងារដែលត្រូវធ្វើបន្ទាប់ពីកិច្ចប្រជុំផ្សព្វផ្សាយ

បន្ទាប់ពីបានរៀបចំឯកសារខាងលើនេះរួចរាល់ហើយ ក្រុមការងារកសាងផែនការស្រុក ត្រូវដាក់ជូនអភិបាលស្រុកពិនិត្យ និងផ្តល់យោបល់។

**ខ). ក្នុងពេលប្រជុំផ្សព្វផ្សាយ**

**សមាសភាពចូលរួម**

- គណៈអភិបាលស្រុក
- តំណាងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក
- ការិយាល័យ អង្គភាពនានាជុំវិញស្រុក
- ក្រុមការងារកសាងផែនការស្រុក
- ការិយាល័យនានារបស់សាលាស្រុក
- មេឃុំ
- តំណាងសមាគមក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់
- អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល ក្រុមយុវជននានាក្នុងស្រុក
- តំណាងវិស័យឯកជនក្នុងស្រុក
- អ្នកពាក់ព័ន្ធផ្សេងទៀត តាមការចាំបាច់។ល។

**ដំណើរការ**

អភិបាលនៃគណៈអភិបាលស្រុកដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយនេះ។ តាមការប្រគល់សិទ្ធិពីប្រធានអង្គប្រជុំ តំណាងក្រុមការងារកសាងផែនការស្រុក ធ្វើបទបង្ហាញជូនអង្គប្រជុំតាមលំដាប់លំដោយ ដូចខាងក្រោម ៖

- គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា
- សេចក្តីណែនាំរបស់ក្រុមប្រឹក្សាស្រុកស្តីពីការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ប្រតិទិនការងាររៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- របៀបបំពេញតារាង និងទម្រង់ធាតុចូល
    - ទម្រង់ទី២ ៖ ធាតុចូលពីរដ្ឋបាលស្រុក
    - ទម្រង់ទី៣ ៖ ធាតុចូលពីការិយាល័យ អង្គភាពជំនាញ
    - ទម្រង់ទី៤ ៖ ធាតុចូលពីអង្គការសង្គមស៊ីវិល និងវិស័យឯកជន
    - ទម្រង់ទី៥ ៖ ធាតុចូលពីរដ្ឋបាលឃុំ

បន្ទាប់ពីការធ្វើបទបង្ហាញ ប្រធានអង្គប្រជុំបើកការពិភាក្សា និងពន្យល់ បំភ្លឺ រួចអភិបាលស្រុកបូក សរុប ផ្តាំផ្ញើ និងបិទកិច្ចប្រជុំផ្សព្វផ្សាយ។

**គ). ការងារក្រោយកិច្ចប្រជុំផ្សព្វផ្សាយ**

**ចំពោះអ្នកពាក់ព័ន្ធត្រូវបំពេញតារាង**

បន្ទាប់ពីបានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអំពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក អ្នកពាក់ព័ន្ធ នៅតាមការិយាល័យ អង្គភាព អង្គការសង្គមស៊ីវិល និងវិស័យឯកជន។ល។ ត្រូវបំពេញតារាងរបស់ខ្លួន តាមការណែនាំក្នុងពេលប្រជុំផ្សព្វផ្សាយ រួចបញ្ជូនតារាងបានបំពេញរួចរបស់ខ្លួន មកក្រុមការងារកសាង ផែនការស្រុកឲ្យបានទាន់តាមកាលកំណត់។

ក្នុងការបំពេញទម្រង់ទី៣របស់ការិយាល័យ អង្គភាពជំនាញ ពិសេសតារាងប្រតិបត្តិការសេវារដ្ឋ បាល ការិយាល័យ អង្គភាពជំនាញសាមីនីមួយៗគប្បីពិចារណាលើ ៖

- ប្រភេទ និងចំនួនសេវារដ្ឋបាល ដែលការិយាល័យ អង្គភាពខ្លួនបានផ្តល់ជូនប្រជាពលរដ្ឋក្នុង ឆ្នាំកន្លងទៅ
- ការប៉ាន់ប្រមាណអំពីប្រភេទ និងបរិមាណនៃសេវានានាទាំងនោះសម្រាប់ឆ្នាំបន្ទាប់
- ស្រង់ប្រភេទ និងចំនួនសេវា ចូលក្នុងតារាងប្រតិបត្តិការសេវានៃទម្រង់ទី៣

## ២.២. ការចូលរួមវេទិកាពិគ្រោះយោបល់នៅថ្នាក់ខេត្ត

បន្ទាប់ពីបានទទួលទម្រង់ទី៥ពីឃុំ ក្រុមការងារកសាងផែនការស្រុកត្រូវពិនិត្យ សរុប និងកែ សម្រួលតារាង១.១.ក.តារាងតម្រូវការគម្រោង សកម្មភាពអាទិភាពទូទាំងស្រុក (ដែលបានរៀបចំក្នុង ជំហានទី១) ដោយរៀបចំតារាង១.១.ខ ៖

- ពិនិត្យ និងធ្វើបច្ចុប្បន្នភាពឡើងវិញនូវគម្រោងអាទិភាពរបស់ស្រុក (ដោយដកចេញគម្រោង ណាដែលមិនចាំបាច់ និងបន្ថែម ឬប្តូរគម្រោងតាមជាក់ស្តែង) និងស្រង់ចូលផ្នែក"ក" នៃ តារាង១.១.ខ។
- ក្នុងករណីមានការកែសម្រួលផ្នែក "ខ" នៃតារាងទី១.១.ក ក្រុមការងារកសាងផែនការស្រុក ត្រូវពិនិត្យ និងកែសម្រួល រួចស្រង់ចូលក្នុងផ្នែក "ខ" នៃតារាងទី១.១.ខ។
- ពិនិត្យ និងស្រង់គម្រោងអាទិភាពរបស់ឃុំនីមួយៗដើម្បីដាក់បញ្ចូលក្នុងផ្នែក"គ"នៃតារាងទី ១.១.ខ។

បន្ទាប់ពីរៀបចំតារាង ១.១.ខ ហើយ ក្រុមការងារកសាងផែនការស្រុកត្រូវរៀបចំបំពេញទម្រង់ទី៤ របស់ខេត្ត។ អភិបាលស្រុកត្រូវចាត់ចែងបញ្ជូនទម្រង់ទី៤របស់ខេត្តទៅឲ្យក្រុមការងារកសាងផែនការខេត្ត តាមកាលបរិច្ឆេទដែលបានកំណត់ សម្រាប់រៀបចំវេទិកាពិគ្រោះយោបល់ស្តីពីការកសាងកម្មវិធីវិនិយោគ បីឆ្នាំរំកិលនៅថ្នាក់ខេត្ត។ ជាមួយគ្នានេះ អភិបាលស្រុកត្រូវត្រៀមរៀបចំមន្ត្រី និងឧបករណ៍នានាសម្រាប់ ចូលរួមក្នុងវេទិកាពិគ្រោះយោបល់នៅថ្នាក់ខេត្ត តាមការអញ្ជើញ។

តារាង១.១.ខ ៖ តម្រូវការគម្រោង សកម្មភាពអាទិភាពទូទាំងស្រុកដែលបានធ្វើបច្ចុប្បន្នភាព

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតប គោលដៅ | ទីតាំង | លទ្ធផល | | រយៈពេល | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| ក. តម្រូវការគម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគស្រុក | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ខ. តម្រូវការគម្រោងដែលស្រុក ស្នើសុំបញ្ចូលទៅក្នុងកម្មវិធីវិនិយោគខេត្ត | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| គ. គម្រោង សកម្មភាពអាទិភាពសម្រាប់កម្មវិធីវិនិយោគឃុំ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

បន្ទាប់ពីបានចូលរួមក្នុងវេទិកាពិគ្រោះយោបល់ពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅខេត្ត ក្រុមការងារកសាងផែនការស្រុក ត្រូវជូនព័ត៌មានស្តីពីលទ្ធផលរបស់វេទិកាពិគ្រោះយោបល់នេះ ដល់គ្រប់អ្នកពាក់ព័ន្ធ និងណែនាំឲ្យមានការពិនិត្យ កែសម្រួល និងរៀបចំឯកសារចាំបាច់សម្រាប់ចូលរួមសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅស្រុក។

## ២.៣. សិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅស្រុក

**គោលបំណង**

ការរៀបចំសិក្ខាសាលាសមារណកម្មកម្មវិធីវិនិយោគនៅស្រុក គឺដើម្បី ៖

- បង្កឱកាសគាំទ្រគម្រោង សកម្មភាពវិនិយោគរបស់ស្រុក និងឃុំ ដែលពុំមានមូលនិធិអនុវត្ត
- សម្របសម្រួល និងបន្សុីគ្នារវាង ៖
  - គម្រោង សកម្មភាពវិនិយោគស្រុក និងឃុំ
  - គម្រោង សកម្មភាពវិនិយោគឃុំ និងឃុំ
  - គម្រោង សកម្មភាពវិនិយោគស្រុក និងមន្ទីរ វិស័យ និងបណ្តាដៃគូអភិវឌ្ឍន៍
  - គម្រោង សកម្មភាពវិនិយោគឃុំ និងមន្ទីរ វិស័យ និងបណ្តាដៃគូអភិវឌ្ឍន៍
- ពង្រឹងកិច្ចសហការរវាងរដ្ឋបាលស្រុក ជាមួយរដ្ឋបាលឃុំ និងភាគីពាក់ព័ន្ធនានា

**លទ្ធផលរំពឹងទុក**

លទ្ធផលរំពឹងទុកដែលនឹងបានពីការធ្វើសិក្ខាសាលាសមាហរណកម្មនៅស្រុកគឺ មានការចុះកិច្ចព្រមព្រៀងបណ្តោះអាសន្នលើការផ្តល់ការគាំទ្រ និងការទទួលយកការគាំទ្ររវាងភាគីអ្នកគាំទ្រ ឬដៃគូអភិវឌ្ឍន៍ និងភាគីអ្នកស្នើសុំការគាំទ្រទាំងបច្ចេកទេសហិរញ្ញវត្ថុ (រដ្ឋបាលឃុំ និងរដ្ឋបាលស្រុក)។

**សមាសភាពចូលរួម**

សិក្ខាសាលាសមាហរណកម្មនៅស្រុកមាន ៖

- តំណាងក្រុមប្រឹក្សាស្រុក

- អភិបាលស្រុក ឬតំណាងគណៈអភិបាលស្រុក
- តំណាងថ្នាកដឹកនាំខេត្ត
- តំណាងមន្ទីរផែនការ
- ក្រុមការងារកសាងផែនការស្រុក
- តំណាងថ្នាក់ដឹកនាំមន្ទីរជំនាញខេត្ត អង្គភាព និងការិយាល័យជំនាញនានានៅថ្នាក់ស្រុក
- មេឃុំ ស្មៀនឃុំ សមាជិកក្រុមប្រឹក្សាឃុំ ឬមេភូមិមួយចំនួន តាមការចាំបាច់
- តំណាងសមាគមក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់
- អ្នកទទួលបន្ទុកកិច្ចនារី និងកុមារឃុំ
- តំណាងអង្គការសង្គមស៊ីវិល ក្រុមយុវជន និងវិស័យឯកជនក្នុងស្រុក
- អ្នកពាក់ព័ន្ធផ្សេងទៀត។ល។

**ដំណើរការ**

**ក). ការងារមុនដំណើរការសិក្ខាសាលាសមាហរណកម្មនៅស្រុក**

**រដ្ឋបាលស្រុកបំពេញការងារ ៖**

- រៀបចំទីកន្លែង និងរបៀបវារៈនៃសិក្ខាសាលាសមាហរណកម្ម
- តាមការឯកភាពពីអភិបាលស្រុក រៀបចំលិខិតអញ្ជើញគណៈអធិបតី ភ្ញៀវកិត្តិយស តំណាងមន្ទីរ អង្គភាព និងអ្នកពាក់ពន្ធ័នានា ដើម្បីចូលរួមសិក្ខាសាលាសមាហរណកម្ម តាមទីកន្លែង និងពេលវេលា ដែលបានកំណត់ ។
- ធ្វើការជូនដំណឹងឱ្យបានទូលំទូលាយអំពីសិក្ខាសាលាសមាហរណកម្មនៅស្រុក ដើម្បីមានការចូលរួមពីសាធារណជន អង្គការសង្គមស៊ីវិល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានាបានច្រើន ។

**ក្រុមការងារកសាងផែនការស្រុកបំពេញការងារ ៖**

បន្ទាប់ពីទទួលបានព័ត៌មានអំពីលទ្ធភាពថវិកាដែលរដ្ឋបាលស្រុកអាចមាន ក្រុមការងារកសាងផែនការស្រុកត្រូវពិនិត្យមើលតារាង១.១.៥ ផ្នែក "ក" ដែលបានរៀបចំខាងលើ ដើម្បីពិនិត្យមើលថាតើថវិការបស់រដ្ឋបាលស្រុកមានចំនួនប៉ុន្មាន ហើយគួរគាំទ្រការអនុវត្តគម្រោងអាទិភាពណាខ្លះ?។ ក្នុងការពិនិត្យ និងសម្រេចជាបណ្តោះអាសន្ននេះលើការជ្រើសរើសគម្រោងអាទិភាព ដើម្បីប្រើប្រាស់ថវិកាស្រុកនេះ ក្រុមការងារកសាងផែនការស្រុកត្រូវ ៖

- ជ្រើសរើសគម្រោង ឬសកម្មភាពសម្រាប់ប្រើប្រាស់មូលនិធិមានភ្ជាប់លក្ខខណ្ឌ ដោយផ្អែកតាមអាទិភាពនៃសំណើគម្រោងក្នុងផ្នែកនីមួយៗ
- ជ្រើសរើសគម្រោង ឬសកម្មភាពដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារជាកាតព្វកិច្ច
- បន្ទាប់មក បន្តជ្រើសរើសគម្រោងអាទិភាពនានា សម្រាប់ប្រើប្រាស់ថវិកាស្រុក ដែលមិនមានភ្ជាប់លក្ខខណ្ឌ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ក្នុងការជ្រើសរើសនេះ ក្រុមការងារកសាងផែនការស្រុកគួរពិចារណាបន្ថែមទៀតលើ ៖

- តុល្យភាពនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគម្រោងសេវានានា
- គម្រោងដែលឆ្លើយតបទៅនឹងតម្រូវការស្ត្រី កុមារ យុវជន ជនពិការ និងជនងាយរងគ្រោះ (បរិយាប័ន្ន និងសមធម៌សង្គម)
- គម្រោងដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ល។

- បន្ទាប់មក ក្រុមការងារកសាងផែនការស្រុក ត្រូវរៀបចំតារាង១.១.គ.តម្រូវការគម្រោងអភិវឌ្ឍន៍សម្រាប់កម្មវិធីវិនិយោគស្រុក ដោយស្រង់ចេញពីផ្នែក "ក" នៃតារាង១.១.ខ និងបន្ថែមប្រភពថវិកាតាមការពិនិត្យ ពិចារណា និងសម្រេចខាងលើ។

តារាង១.១.គ ៖ តម្រូវការគម្រោង សកម្មភាពអាទិភាពរបស់រដ្ឋបាលស្រុក

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ឆ្លើយតប គោលដៅ | ទី តាំង | លទ្ធផល | | រយៈ ពេល | អ្នកទទួលផល | | តម្លៃប៉ាន់ ស្មាន | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

- បន្ទាប់ពីរៀបចំតារាង១.១.គរួច ក្រុមការងារកសាងផែនការស្រុកត្រូវបន្តរៀបចំរបាយការណ៍អនុវត្តគម្រោង សកម្មភាពនៃកម្មវិធីវិនិយោគ ដោយប្រៀបធៀបជាមួយគម្រោង សកម្មភាពដែលមានការសន្យាមូលនិធិគាំទ្រអនុវត្តក្នុងឆ្នាំកន្លងមកតាមតារាង១.២.ដោយពិនិត្យបូកសរុប និងផ្ទៀងផ្ទាត់ជាមួយទម្រង់ទី២ ដែលទទួលបានពីរដ្ឋបាលស្រុក ដូចខាងក្រោម ៖

តារាង១.២ ៖ លទ្ធផលនៃការអនុវត្តគម្រោងក្នុងឆ្នាំ.................

| លរ. | ឈ្មោះគម្រោង | ផ្នែក | ទីតាំង | លទ្ធផលគ្រោង | | តម្លៃប៉ាន់ស្មាន (លានរៀល) | អ្នកទទួលផល | | ប្រភពអ្នកគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | |
| **គម្រោងប្រើប្រាស់មូលនិធិស្រុក** | | | | | | | | | |
| ក. បានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ខ. កំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| គ. មិនបានអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| **គម្រោងស្រុកដែលមានថវិកាគាំទ្រ** | | | | | | | | | |
| ឃ. បានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ង. កំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ច. មិនបានអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| **គម្រោងដែលបានអនុវត្តមិនមានថវិកាគាំទ្រ និងក្រៅសំណើសុំការគាំទ្រ** | | | | | | | | | |
| ឆ. បានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ជ. កំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

**កំណត់សម្គាល់ ៖**

+ គម្រោងកំពុងអនុវត្ត គឺជាគម្រោងដែលមិនអាចអនុវត្តចប់ក្នុងឆ្នាំថវិកា និងត្រូវអនុវត្តបន្តនៅឆ្នាំបន្ទាប់
+ គម្រោងបានអនុវត្តរួចជាស្ថាពរ គឺជាគម្រោងដែលបានបញ្ចប់១០០% ក្នុងឆ្នាំថវិកា។
+ គម្រោងមិនបានអនុវត្ត គឺជាគម្រោងដែលមានថវិកាគាំទ្រ ប៉ុន្តែមិនបានអនុវត្តរហូតដល់ដាច់ឆ្នាំថវិកា(គម្រោងប្រភេទនេះ បើនៅមានការសន្យាគាំទ្រនឹងក្លាយជាគម្រោង មានការសន្យានៅឆ្នាំបន្ទាប់)។

- សហការជាមួយរដ្ឋបាលស្រុករៀបចំសុន្ទរកថាបើក បិទសិក្ខាសាលា និងសំណុំឯកសារត្រូវប្រើក្នុងសិក្ខាសាលាជូនអភិបាលស្រុកជាប្រធានគណៈអធិបតីក្នុងសិក្ខាសាលា
- បន្ទាប់ពីរៀបចំតារាង ១.១.គ និង ១.២. ហើយ ក្រុមការងារកសាងផែនការស្រុក ត្រូវបញ្ជូនទៅឲ្យមន្ទីរផែនការ និងស្នើឲ្យមន្ទីរផែនការខេត្តរៀបចំតារាងបូកសរុបគម្រោង សកម្មភាពវិនិយោគអាទិភាពរបស់ស្រុក (តារាងម៉ាទ្រិច)
- រៀបចំឯកសារពាក់ព័ន្ធនានាផ្សេងទៀត តាមការចាំបាច់។

**ខ). ការងារក្នុងពេលដំណើរការសិក្ខាសាលាសមាហរណកម្ម**

សិក្ខាសាលាសមាហរណកម្មនៅស្រុក ប្រព្រឹត្តទៅក្រោមអធិបតីភាពអភិបាលស្រុក និងដំណើរការតាមរបៀបវារៈសំខាន់ៗដូចខាងក្រោម ៖

- ប្រកាសហេតុ ដោយអ្នកសម្របសម្រួលកម្មវិធី
- សុន្ទរកថាស្វាគមន៍ និងបើកសិក្ខាសាលា ដោយអភិបាលស្រុក
- តំណាងក្រុមការងារកសាងផែនការស្រុកបង្ហាញ ៖
  - លទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគឆ្នាំមុន
  - បញ្ជីគម្រោង សកម្មភាពអាទិភាពរបស់ស្រុក ដែលបានសម្រេចបណ្តោះអាសន្នក្នុងការប្រើប្រាស់មូលនិធិស្រុក
  - បញ្ជីគម្រោង សកម្មភាពអាទិភាពរបស់ស្រុកដែលមិនទាន់មានថវិកាគាំទ្រ
- តំណាងឃុំនីមួយៗធ្វើការបង្ហាញពី ៖
  - លទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគឆ្នាំមុន
  - បញ្ជីគម្រោង សកម្មភាពអាទិភាពរបស់ឃុំ ដែលបានសម្រេចបណ្តោះអាសន្នក្នុងការប្រើប្រាស់មូលនិធិឃុំ
  - បញ្ជីគម្រោង សកម្មភាពអាទិភាពរបស់ឃុំដែលមិនទាន់មានមូលនិធិគាំទ្រ
- សមាជិក សមាជិកានៃអង្គសិក្ខាសាលាធ្វើការពិភាក្សា បំភ្លឺ ពន្យល់ ផ្តល់ការគាំទ្រ
- ការចុះកិច្ចព្រមព្រៀងបណ្តោះអាសន្ន

ដោយមានការគាំទ្រពីមន្ទីរផែនការ ក្រុមការងារកសាងផែនការស្រុកត្រូវបូកសរុប និងរាយការណ៍ភ្លាមៗពីលទ្ធផលបណ្តោះអាសន្ននៃអង្គសិក្ខាសាលា។ ចុងក្រោយអភិបាលស្រុកផ្តែផ្តាំការងារដែលត្រូវធ្វើបន្ត និងបិទអង្គសិក្ខាសាលា។

**២.៤. ចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក**

បន្ទាប់ពីបញ្ចប់សិក្ខាសាលាសមាហរណកម្មនៅស្រុក ការងារដែលត្រូវធ្វើបន្ទាន់មាន ៖

- ការិយាល័យផែនការស្រុក ដោយមានការគាំទ្របច្ចេកទេសពីមន្ទីរផែនការត្រូវប្រមូល និងបញ្ចូលទិន្នន័យស្តីពីកិច្ចព្រមព្រៀងបណ្តោះអាសន្ន ចូលក្នុងកម្មវិធីគ្រប់គ្រងទិន្នន័យគម្រោងអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ (SPD) ដើម្បីរៀបចំរបាយការណ៍ចុងក្រោយជូនអ្នកពាក់ព័ន្ធ។
- ក្រុមការងារកសាងផែនការស្រុកត្រូវ ៖

- ពិនិត្យ និងកែសម្រួលគម្រោង សកម្មភាពវិនិយោគ ដែលមានការសន្យាគាំទ្រពីបណ្ដាមន្ទីរ អង្គភាព អង្គការជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធនានា។ ករណីមិនច្បាស់ ត្រូវពិគ្រោះជាមួយភាគីពាក់ព័ន្ធដែលបានសន្យាគាំទ្រក្នុងសិក្ខាសាលាសមាហរណកម្មនៅស្រុក។
- បន្ទាប់មក ដោយផ្អែកតាមតារាង១.១.គ លទ្ធផលនៃសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក និងទម្រង់ទី២ ទម្រង់ទី៣ និងទម្រង់ទី៤ដែលទទួលបានពីអ្នកពាក់ព័ន្ធ ក្រុមការងារកសាងផែនការស្រុកត្រូវរៀបចំ ៖

+ តារាង២.១ ៖ សង្ខេបប្រភពមូលនិធិ
+ តារាង២.២ ៖ គម្រោង សកម្មភាពកំពុងដំណើរការ
+ តារាង២.៣ ៖ គម្រោង សកម្មភាពស្រុកដែលមានថវិកាគាំទ្រ
+ តារាង២.៤ ៖ គម្រោង សកម្មភាពស្រុកដែលមិនទាន់មានថវិកាគាំទ្រ

និងរៀបចំតារាង

+ តារាង ២.៥ ៖ កម្មវិធីប្រតិបត្តិការសេវារដ្ឋបាល
+ តារាង ២.៦ ៖ ការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលស្រុក
+ តារាង ២.៧ ៖ គម្រោង សកម្មភាពរបស់ក្រសួង ស្ថាប័ន កំពុងអនុវត្តក្នុងដែនដីស្រុក

(ទម្រង់តារាងខាងលើ មាននៅក្នុងផ្នែកទី២នៃសេចក្ដីណែនាំបច្ចេកទេសនេះ)

ក្រុមការងារកសាងផែនការស្រុក រៀបចំសេចក្ដីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកដោយផ្អែកតាមមាតិកានៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ដោយត្រូវសរសេរបរិយាយ និងចងក្រងសេចក្ដីព្រាងស្របតាមសេចក្ដីពន្យល់ដែលមានក្នុងផ្នែកទី២នៃសេចក្ដីណែនាំនេះ។

## ២.៥. ការរៀបចំតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ

ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកអាចធ្វើឡើងត្រឹមក្របខណ្ឌគម្រោង ឬសកម្មភាពទោល និងឬអាចធ្វើឡើងសម្រាប់កម្មវិធីទាំងមូល។

ដើម្បីឲ្យការអនុវត្តការតាមដាន និងវាយតម្លៃការអនុវត្តគម្រោង សកម្មភាពក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកមានប្រសិទ្ធភាព និងមានប្រយោជន៍នោះ អភិបាលស្រុកដោយបានការឯកភាពពីក្រុមប្រឹក្សាស្រុកណែនាំឲ្យក្រុមការងារកសាងផែនការស្រុករៀបចំគោលការណ៍ និងនីតិវិធីប្រតិបត្តិការដែលមាន ៖

- ក្របខ័ណ្ឌតាមដាន វាយតម្លៃ (យុទ្ធសាស្ត្រ វិធីសាស្ត្រ ផែនការសកម្មភាព)
- ការបែងចែកភារកិច្ចដល់អ្នកពាក់ព័ន្ធក្នុងការតាមដាន និងវាយតម្លៃ (យន្តការ ភារកិច្ច)
- តារាងតាមដានការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

## តារាងតាមដានការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

| ល.រ. | ឈ្មោះគម្រោង | គ្រោង/ ជាក់ស្តែង | លទ្ធផល | | រយៈ ពេល អនុវត្ត | តម្លៃ គម្រោង | អង្គភាព អនុវត្ត | % នៃការ សម្រេច | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | | |
| **១.គម្រោងវិនិយោគរបស់រដ្ឋបាលស្រុក** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **២. កម្មវិធីប្រតិបត្តិការសេវារដ្ឋបាលរបស់រដ្ឋបាលស្រុក** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **៣. ការដាក់ចេញលិខិតបទដ្ឋានរបស់រដ្ឋបាលស្រុក** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |

## តារាងតាមដានការអនុវត្ត
## គម្រោងវិនិយោគ និងការប្រតិបត្តិការសេវារបស់ការិយាល័យជំនាញ

| ល.រ. | ឈ្មោះគម្រោង | គ្រោង/ ជាក់ស្តែង | លទ្ធផល | | រយៈ ពេល អនុវត្ត | តម្លៃ គម្រោង | អង្គភាព អនុវត្ត | % នៃការ សម្រេច | ម្ចាស់ គម្រោង |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | | |
| **១.គម្រោងវិនិយោគរបស់ការិយាល័យជំនាញ** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| **២. កម្មវិធីប្រតិបត្តិការសេវារដ្ឋបាល របស់ការិយាល័យជំនាញ** | | | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |
| | | គ្រោង | | | | | | | |
| | | ជាក់ស្តែង | | | | | | | |

គម្រោងដែលត្រូវស្រង់បញ្ចូលក្នុងតារាងខាងលើ គឺ ៖

- គម្រោង សកម្មភាពដែលមានថវិកាគាំទ្រ និង
- គម្រោង សកម្មភាពកំពុងដំណើរការ។

## ២.៦. ការពិនិត្យ និងផ្តល់យោបល់

បន្ទាប់ពីរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកហើយ ក្រុមការងារកសាងផែនការស្រុក ត្រូវ ៖

- ដាក់សេចក្តីព្រាងសៀវភៅនេះ ជូនទៅគណៈអភិបាលស្រុក ដើម្បីពិនិត្យ និងផ្តល់យោបល់
- ពិនិត្យ និងកែសម្រួលសេចក្តីព្រាងសៀវភៅ តាមមតិយោបល់ និងអនុសាសន៍របស់គណៈអភិបាល
- ដាក់សេចក្តីព្រាងសៀវភៅនេះ ជូនទៅគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសស្រុក ដើម្បីពិនិត្យ និងផ្តល់យោបល់
- ពិនិត្យ និងកែសម្រួលសេចក្តីព្រាងសៀវភៅ តាមមតិយោបល់ និងអនុសាសន៍របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសស្រុក
- ដាក់សេចក្តីព្រាងចុងក្រោយជូនអភិបាលស្រុក ដើម្បីបញ្ជូនទៅក្រុមប្រឹក្សាស្រុក។

# ជំហានទី៣

# ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយ

# សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

## គោលបំណង

គោលបំណងនៃជំហាននេះ គឺដើម្បីពិនិត្យ អនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកស្របតាមខ្លឹមសារនៃមាត្រា៣៦ និងមាត្រា៣៧នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## លទ្ធផលរំពឹងទុក

សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក បានចូលជាធរមាន និងមានតម្លៃគតិយុត្តក្នុងការប្រើប្រាស់។

## ដំណើរការ

សកម្មភាពសំខាន់ក្នុងជំហានទី៣នេះ រួមមាន ៖

៣.១. កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

៣.២. ការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

## ៣.១. កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

បន្ទាប់ពីទទួលបានសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកពីអភិបាលស្រុក ក្រុមប្រឹក្សាស្រុកត្រូវរៀបចំកិច្ចប្រជុំពិនិត្យ និងអនុម័តក្នុងសម័យប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាស្រុក។

ដើម្បីជានាភាពរលូន និងជោគជ័យក្នុងកិច្ចប្រជុំពិនិត្យ និងអនុម័តសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ការងារដែលត្រូវធ្វើមានដូចខាងក្រោម ៖

### មុនកិច្ចប្រជុំ

ក្រុមការងារកសាងផែនការស្រុក ដោយមានជំនួយពីនាយករដ្ឋបាលសាលាស្រុក ត្រូវរៀបចំ ៖

- របៀបវារៈនៃកិច្ចប្រជុំ
- រៀបចំសេចក្តីថ្លែងហេតុជូនអភិបាលស្រុក ដោយមានសង្ខេបដំណើរការ និងខ្លឹមសារនៃសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ថតចម្លងសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកទុកចែកជូនអ្នកចូលរួមប្រជុំ
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញដោយភ្ជាប់ជាមួយនូវសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ស្រុក ទៅអ្នកពាក់ព័ន្ធឲ្យបានយ៉ាងតិច៣ថ្ងៃមុនថ្ងៃប្រជុំ (ដោយនាយករដ្ឋបាលនៃសាលាស្រុក)
- រៀបចំកិច្ចការចាំបាច់ផ្សេងៗទៀតតាមការណែនាំរបស់អភិបាលស្រុក ឬក្រុមប្រឹក្សាស្រុក។

### ក្នុងពេលប្រជុំ

#### សមាសភាពចូលរួម

- សមាជិកក្រុមប្រឹក្សាស្រុក
- គណៈអភិបាលស្រុក
- នាយករដ្ឋបាលសាលាស្រុក
- ក្រុមការងារកសាងផែនការស្រុក
- ក្រុមលេខាកត់ត្រារបស់ក្រុមប្រឹក្សាស្រុក
- តំណាងការិយាល័យ អង្គភាព និងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់។

### ដំណើរការកិច្ចប្រជុំ

សកម្មភាពក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុកនេះ រួមមាន ៖

- ប្រធានក្រុមប្រឹក្សាស្រុកបើកអង្គប្រជុំ និងដឹកនាំការប្រជុំ
- អភិបាលស្រុក អានសេចក្តីថ្លែងហេតុជូនអង្គប្រជុំ
- តាមការចាត់តាំងពីអភិបាលស្រុក និងមានការឯកភាពពីប្រធានអង្គប្រជុំ តំណាងក្រុមការងារកសាងផែនការស្រុកបង្ហាញខ្លឹមសារសំខាន់ៗនៃសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- ក្រុមប្រឹក្សាស្រុកពិនិត្យ ពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក (ឯកសារជំនួយស្មារតីមាននៅក្នុងឧបសម្ព័ន្ធទី៥ផ្នែកទី៤)
- ក្រុមប្រឹក្សាស្រុកអនុម័តលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាស្រុក។

### ក្រោយកិច្ចប្រជុំ

បន្ទាប់ពីកិច្ចប្រជុំក្រុមប្រឹក្សាស្រុក ក្រុមការងារកសាងផែនការស្រុកត្រូវ ៖

- ធ្វើការកែតម្រូវបណ្តាចំណុចក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក តាមការសម្រេចរបស់ក្រុមប្រឹក្សាស្រុក
- រៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក
- យកសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកដែលបានកែតម្រូវចុងក្រោយ និងសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ជូនអភិបាលស្រុកពិនិត្យ។
- ពិនិត្យរួច អភិបាលស្រុកយកសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក ដោយមានអមជាមួយនូវសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកដែលបានកែតម្រូវចុងក្រោយ ជូនប្រធានក្រុមប្រឹក្សាស្រុកពិនិត្យ ចុះហត្ថលេខា។

## ៣.២. ការបោះពុម្ព និងផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

### ការបោះពុម្ពសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

អភិបាលនៃគណៈអភិបាលស្រុក ពិនិត្យ និងណែនាំដល់នាយករដ្ឋបាលសាលាស្រុក ដើម្បីបោះពុម្ពសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក តាមចំនួនដែលបានកំណត់។

### ការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

តាមការឯកភាពយោបល់រវាងក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកត្រូវបានតំកល់នៅសាលាស្រុក រដ្ឋបាលខេត្ត ទីចាត់ការផែនការ និងវិនិយោគខេត្ត) មន្ទីរផែនការខេត្ត មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត និងជូនអ្នកពាក់ព័ន្ធតាមការចាំបាច់។

ជាមួយនឹងការផ្សព្វផ្សាយតាមការចែកសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក អភិបាលស្រុកគប្បីណែនាំឲ្យមានការផ្សព្វផ្សាយខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុកឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ដូចជាផ្សព្វផ្សាយក្នុងកិច្ចប្រជុំនានា ក្នុងវេទិកាសាធារណៈ តាមសារព័ត៌មានវិទ្យុក្នុងស្រុក និងតាមមធ្យោបាយផ្សេងៗទៀតដែលអាចធ្វើបាន។ល។ លើសពីនេះទៀត អភិបាលស្រុកត្រូវណែនាំឲ្យក្រុមការងារកសាងផែនការស្រុករៀបចំទម្រង់ទី៦បញ្ជីគម្រោង (គម្រោងដែលមានការសន្យាគាំទ្រ និងគម្រោងកំពុងអនុវត្ត) នៅតាមឃុំនីមួយៗដោយឡែកៗពីគ្នា ដើម្បីផ្ញើទៅឲ្យឃុំសាមីសម្រាប់ផ្សព្វផ្សាយជូនប្រជាពលរដ្ឋ។

# ផ្នែកទី៤

# ឧបសម្ព័ន្ធជាជំនួយស្មារតី

# នៅពេលកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលស្រុក**........... ...........ថ្ងៃទី...........ខែ...........ឆ្នាំ...........

លេខ ៖---------------

# សេចក្តីណែនាំ

# ស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក....

(សេចក្តីណែនាំគប្បីសរសេរជា៦ កថាខណ្ឌ)

កថាខណ្ឌទី១ ៖ ជាសេចក្តីផ្តើមនៃសេចក្តីណែនាំ ដោយសរសេររៀបរាប់ពីចំណុចសំខាន់ៗរបស់ឯកសារគតិយុត្តដែលពាក់ព័ន្ធនឹងតួនាទីរបស់ក្រុមប្រឹក្សាស្រុកក្នុងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដូចជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

កថាខណ្ឌទី២ ៖ សរសេររៀបរាប់សង្ខេបពីស្ថានភាពទូទៅក្នុងស្រុក (សេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិនិងបរិស្ថាន រហូតដល់រដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ)។ ការសរសេររៀបរាប់នេះ គប្បីមានរំលេចទាំងភាពល្អប្រសើរ និងភាពមិនទាន់ល្អប្រសើរ។ មូលដ្ឋានព័ត៌មានសម្រាប់សរសេរ គឺស្រង់ចេញពីឯកសារពិន្ទុតាម វិស័យរបស់ស្រុក ដែលមន្ទីរផែនការខេត្តចងក្រងចេញពីទិន្នន័យមូលដ្ឋានឃុំ។

កថាខណ្ឌទី៣ ៖ សរសេរពីគោលបំណង និងទិសដៅនៃការអភិវឌ្ឍស្រុកនៅឆ្នាំខាងមុខ។ ក្នុងវាក្យខណ្ឌនេះ ត្រូវបង្ហាញពីវិស័យណាខ្លះដែលស្រុកមានគំនិតចាត់ទុកជាអាទិភាព ដែលចង់ឲ្យអ្នកពាក់ព័ន្ធពិចារណា និងរៀបចំគម្រោង សកម្មភាពក្នុងវិស័យខ្លួន ដើម្បីឆ្លើយតប និងដោះស្រាយ។

កថាខណ្ឌទី៤ ៖ សរសេរពីតួនាទីរបស់អ្នកពាក់ព័ន្ធ ដែលត្រូវប្រតិបត្តិក្នុងដំណើរប្រព្រឹត្តទៅនៅពេលរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

កថាខណ្ឌទី៥ ៖ សរសេរអំពីប្រតិទិននៃការអនុវត្តតាមជំហាននីមួយៗក្នុងដំណោះរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក។

កថាខណ្ឌទី៦ ៖ សរសេរមានន័យដែលមានលក្ខណៈបញ្ជា ដូចជា *ទទួលបានសេចក្តីណែនាំនេះ ក្រុមការងារកសាងផែនការស្រុក ប្រធានអង្គភាពជុំវិញស្រុក អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានាល។ល។ត្រូវចាត់ចែងផ្សព្វផ្សាយ និងអនុវត្តឲ្យមានប្រសិទ្ធភាព។*

ហត្ថលេខានិងត្រា

ប្រធានក្រុមប្រឹក្សាស្រុក

ចម្លងជូន ៖

- ក
- ខ

ឧបសម្ព័ន្ធទី២ ÷ ទម្រង់ធាតុចូល

## ទម្រង់ទី១
## ធាតុចូលអំពីការវិភាគស្ថានភាព និងតម្រូវការអភិវឌ្ឍន៍

### ១). ការវិភាគស្ថានភាព

- ចំណុចខ្លាំង
- ចំណុចខ្សោយ/បញ្ហាប្រឈម
- បញ្ហាអាទិភាពសំខាន់ៗដែលត្រូវដោះស្រាយចំពោះមុខ

### ២). តម្រូវការគម្រោង សកម្មភាពជាអាទិភាព

តារាងតម្រូវការគម្រោង សកម្មភាពជាអាទិភាព

| ល.រ | ឈ្មោះគម្រោង | គោលដៅ | ទីតាំង | លទ្ធផលគ្រោង | | រយៈពេល | អ្នកទទួលផល | | តម្លៃ | អង្គភាពស្នើ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| **ក. គម្រោងដែលឃុំ ឬការិយាល័យ អង្គភាពសាមីអាចមានលទ្ធភាពអនុវត្ត** | | | | | | | | | | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤. ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| **ខ. គម្រោងដែលឃុំ ឬអង្គភាពស្នើសុំបញ្ចូលទៅក្នុងកម្មវិធីវិនិយោគស្រុក** | | | | | | | | | | |
| ១. ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៣. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤. ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

អ្នករៀបចំ

បានឃើញ និងឯកភាព

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

**ប្រធានអង្គភាព**

# ទម្រង់ទី២

## ធាតុចូលពីរដ្ឋបាលស្រុក ឆ្នាំ...........

| លរ. | ឈ្មោះគម្រោង | ផ្នែក | ទីតាំង | លទ្ធផលគ្រោង | | តម្លៃប៉ាន់ស្មាន (លានរៀល) | អ្នកទទួលផល | | អ្នកគាំទ្រ |
|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | |
| **គម្រោង សកម្មភាពស្រុកប្រើប្រាស់មូលនិធិស្រុក** | | | | | | | | | |
| ក. បានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ខ. កំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| គ. មិនបានអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| **គម្រោង សកម្មភាពស្រុកដែលមានការសន្យាគាំទ្រ** | | | | | | | | | |
| ឃ. បានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ង. កំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ច. មិនបានអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| **គម្រោង សកម្មភាពស្រុកដែលបានអនុវត្តដោយមិនមានការសន្យាគាំទ្រ ឬគាំទ្រក្រៅសំណើ** | | | | | | | | | |
| ឆ. បានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ជ. កំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

## តារាងកម្មវិធីផ្តល់សេវារដ្ឋបាល ឆ្នាំ.....

| ល.រ | ប្រភេទសេវា | លទ្ធផល | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|
| | | បរិមាណ | ឯកតា | | |
| ក. កម្មវិធីប្រតិបត្តិការសេវារបស់រដ្ឋបាលស្រុក | | | | | |
| | | | | | |
| | | | | | |
| ខ. កម្មវិធីប្រតិបត្តិការសេវារបស់ការិយាល័យជំនាញ | | | | | |
| | | | | | |
| | | | | | |

**តារាងលិខិតបទដ្ឋាននានារបស់រដ្ឋបាលស្រុកដែលត្រូវរៀបចំ និងដាក់ឲ្យប្រើប្រាស់ ឆ្នាំ.....**

| លរ | ប្រភេទលិខិតបទដ្ឋាន | លទ្ធផលគ្រោង | | ផ្សេងៗ |
|---|---|---|---|---|
| | | បរិមាណ | ឯកតា | |
| | | | | |
| | | | | |
| | | | | |

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........
អ្នករៀបចំតារាង

បានឃើញ និងឯកភាព
ថ្ងៃទី................. ខែ............. ឆ្នាំ២០..........
នាយករដ្ឋបាល

## ទម្រង់ទី៣

### ធាតុចូលពីការិយាល័យ អង្គភាព........... ឆ្នាំ..........

| លរ. | ឈ្មោះគម្រោង | ផ្នែក | ទីតាំង | លទ្ធផលគ្រោង | | តម្លៃប៉ាន់ស្មាន (លានរៀល) | អ្នកទទួលផល | | ប្រភពមូលនិធិ |
|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | សរុប | ស្រី | |
| ក. គម្រោងបានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ខ. គម្រោងកំពុងដំណើរការ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| គ. គម្រោងមានការសន្យាគាំទ្រ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| **គម្រោងរបស់ក្រសួងខ្សែបណ្តាយរបស់ការិយាល័យ អង្គភាពសាមី** | | | | | | | | | |
| ឃ. គម្រោងបានអនុវត្តរួចជាស្ថាពរ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ង. គម្រោងកំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........
អ្នករៀបចំតារាង

បានឃើញ និងឯកភាព
ថ្ងៃទី................. ខែ............. ឆ្នាំ២០..........
ប្រធានការិយាល័យ អង្គភាព....

## ទម្រង់ទី៤

### ធាតុចូលពីអង្គការសង្គមស៊ីវិល វិស័យឯកជន........... ឆ្នាំ..........

| លរ. | ឈ្មោះគម្រោង | ផ្នែក | ទីតាំង | លទ្ធផលគ្រោង | | តម្លៃប៉ាន់ស្មាន | អ្នកទទួលផល | | ប្រភពមូលនិធិ |
|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | (លានរៀល) | សរុប | ស្រី | |
| ក. គម្រោងបានអនុវត្តបញ្ចប់ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ខ. គម្រោងកំពុងអនុវត្ត | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| គ. គម្រោងដែលមានថវិកាគាំទ្រ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

បានឃើញ និងឯកភាព
ថ្ងៃទី................. ខែ............. ឆ្នាំ២០..........
ប្រធាន.......

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........
អ្នករៀបចំតារាង

## ទម្រង់ទី៥

### ធាតុចូលពីរដ្ឋបាលឃុំ

| លរ | ឈ្មោះគម្រោងសកម្មភាព | ទីតាំង | លទ្ធផល | | រយៈពេល | អ្នកទទួលផល | | តម្លៃប៉ាន់ស្មាន | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | សរុប | ស្រី | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ២. ផ្នែកសង្គមកិច្ច | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ៣. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

# ទម្រង់ទី៦
# គម្រោងវិនិយោគរបស់ស្រុក
# ដែលត្រូវអនុវត្តក្នុងដែនដីឃុំ................ សម្រាប់ឆ្នាំ...........

| ល.រ | ឈ្មោះគម្រោង | ទីតាំង | ប្រភពថវិកា | ស្ថានភាពគម្រោង | |
|---|---|---|---|---|---|
| | | | | កំពុងដំណើរការ | មានថវិកាគាំទ្រ |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

អ្នករៀបចំតារាង

បានឃើញ និងឯកភាព

ថ្ងៃទី................. ខែ............. ឆ្នាំ២០..........

អភិបាលស្រុក

**ឧបសម្ព័ន្ធទី៣**

## វិធីសាស្ត្រចាត់អាទិភាព

ការចាត់អាទិភាពគម្រោង សកម្មភាព មានវិធីសាស្ត្របួន(០៤)ដែលគេនិយមប្រើ គឺ១).វិធីសាស្ត្រផ្តល់ពិន្ទុផ្អែកលើលក្ខណៈវិនិច្ឆ័យ ២).វិធីសាស្ត្រផ្ទួរផ្គង ៣).វិធីសាស្ត្រជ្រើសរើសដោយដាក់ពិន្ទុ តាមជម្រើស និង ៤).វិធីសាស្ត្រ Pay off matrix។ ក្នុងចំណោមវិធីសាស្ត្រទាំងនេះ វិធីសាស្ត្រផ្តល់ពិន្ទុ ផ្អែកតាមលក្ខណៈវិនិច្ឆ័យ គឺជាវិធីសាស្ត្រសាមញ្ញ។

ក្នុងការអនុវត្តវិធីសាស្ត្រនេះ ក្រុមការងារកសាងផែនការ ឬអ្នកពាក់ព័ន្ធនានាអាចពិចារណា និងអនុវត្តតាមចំណុចនីមួយៗដូចខាងក្រោម ៖

- ស្រង់ជម្រើសនានា ដែលត្រូវចាត់អាទិភាពចូលក្នុងតារាង
- ពិភាក្សា និងកំណត់លក្ខណៈវិនិច្ឆ័យនានា។ ជាទូទៅលក្ខណៈវិនិច្ឆ័យមានការប្រែប្រួលទៅតាមលក្ខណៈនៃជម្រើស ឬបញ្ហា ឬដំណោះស្រាយ។ ជាទូទៅលក្ខណៈវិនិច្ឆ័យដែលចាំបាច់ គួរតែមាននៅគ្រប់ជម្រើស ឬដំណោះស្រាយ គឺការឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ក្រុមងាយរងគ្រោះជាក់លាក់ណាមួយ និងភាពសមធម៌។
- ពិនិត្យជម្រើសនីមួយៗម្តងមួយៗ ដោយធៀបជាមួយលក្ខណៈវិនិច្ឆ័យដែលបានកំណត់។ ពិន្ទុដែលទទួលបានពីការប្រៀបធៀបត្រូវកំណត់ជាលេខ។ ពិន្ទុទាបជាងគេ០១ ហើយពិន្ទុខ្ពស់ជាងគេ គឺជាស្មើនឹងចំនួនជម្រើសសរុប ។

**ឧទាហរណ៍ ៖** អំពីតារាងនៃវិធីផ្តល់ពិន្ទុផ្អែកលើលក្ខណៈវិនិច្ឆ័យ

| ជម្រើស | លក្ខណៈវិនិច្ឆ័យ | | | | | សរុបពិន្ទុ |
|---|---|---|---|---|---|---|
| | ការឆ្លើយតបតម្រូវការ | ការនិយមចូលចិត្ត | ការថែទាំ | សមធម៌ | ប្រសិទ្ធភាពតម្លៃ | |
| គម្រោង "ក" | 2 | 3 | 5 | 1 | 5 | 16 |
| គម្រោង "ខ" | 4 | 5 | 4 | 3 | 4 | 20 |
| គម្រោង "គ" | 3 | 3 | 3 | 2 | 3 | 14 |
| គម្រោង "ឃ" | 5 | 1 | 2 | 4 | 1 | 13 |
| គម្រោង "ង" | 1 | 1 | 2 | 1 | 1 | 6 |

តាមរយៈឧបករណ៍នេះ ក្រុមការងារបានកំណត់យកគម្រោងចំនួន០៥ និងលក្ខណៈវិនិច្ឆ័យចំនួន០៥ មកធ្វើជាសមាសធាតុសម្រាប់រៀបលំដាប់ថ្នាក់អាទិភាពនៃគម្រោង។ តាមការផ្តល់ពិន្ទុក្នុងតារាងខាងលើ យើងឃើញថា ៖

| ជំរើស | អាទិភាព |
|---|---|
| គម្រោង "ខ" | ១ |
| គម្រោង "ក" | ២ |
| គម្រោង "គ" | ៣ |
| គម្រោង "ឃ" | ៤ |
| គម្រោង "ង" | ៥ |

**ឧបសម្ព័ន្ធទី៤**

## វិធីសាស្ត្រវិភាគស្ថានភាព
## វិធីសាស្ត្រវិភាគឯកសារព័ត៌មានស្ថានភាព និងឯកសារពិន្ទុវិស័យ

ក្នុងការវិភាគស្ថានភាពស្រុក ដើម្បីកំណត់ពីតម្រូវការគម្រោងអាទិភាព ក្រុមការងារកសាងផែនការស្រុក ត្រូវធ្វើការវិភាគ និងសន្និដ្ឋានអំពីចំណុចខ្លាំង ចំណុចខ្សោយរបស់វិស័យនីមួយៗ ដោយផ្អែកលើទិន្នន័យភូមិ ទិន្នន័យឃុំ សង្កាត់ ឯកសារព័ត៌មានស្ថានភាពស្រុក និងទិន្នន័យឬព័ត៌មាន (ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ពិន្ទុវិស័យ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ផែនទីសេវាសង្គម...) និងឧបករណ៍វិភាគផ្សេងៗ ដើម្បីកំណត់អំពីបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយនានា។ ក្នុងការវិភាគដោយប្រើប្រាស់ឯកសារព័ត៌មានស្ថានភាព ពិន្ទុវិស័យ ក្រុមការងារកសាងផែនការ ឬ គ.ផ.ថ ត្រូវ ៖

- ពិនិត្យមើលទិន្នន័យ ឬព័ត៌មានដែលមានក្នុងឯកសារព័ត៌មានស្ថានភាពម្តងមួយចំណុចៗ
- ផ្អែកលើទិន្នន័យ និងព័ត៌មាននីមួយៗ តើអ្វីជាបញ្ហាដែលមានការប្រឈមខ្លាំងដល់បុរស ស្ត្រី ជនពិការ កុមារ និងក្រុមជនងាយរងគ្រោះជាក់លាក់ណាមួយ ដែលត្រូវធ្វើការដោះស្រាយ ឬអន្តរាគមន៍?
- បន្ទាប់ពីកំណត់បញ្ហារួច ត្រូវធ្វើការពិភាក្សាដើម្បីកំណត់ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយ
- ស្រង់បញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយចូលក្នុងតារាងដូចខាងក្រោម។

**បញ្ហា តម្រូវការ និងដំណោះស្រាយ**

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុនៃបញ្ហា | តម្រូវការ | ដំណោះស្រាយ | ផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ក្រៅពីវិធីសាស្ត្រខាងលើនេះ ក្រុមការងារកសាងផែនការអាចប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រផ្សេងៗទៀតដូចជា ដើមឈើបញ្ហា ការវិភាគការប្រែប្រួលអាកាសធាតុ ស្វត... តាមការចាំបាច់។

**ឧបសម្ព័ន្ធទី៥**

## ចំណុចគន្លឹះសម្រាប់ក្រុមប្រឹក្សា
## ពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល

ជាជំនួយស្មារតីក្នុងការពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ក្រុមប្រឹក្សាគប្បីយកចិត្តទុកដាក់លើចំណុចគន្លឹះនានាដូចខាងក្រោម ៖

1. តើការរៀបចំសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលស្របតាមមាតិកាដែលបានកំណត់ក្នុងសេចក្ដីណែនាំបច្ចេកទេសដែរឬទេ ?
2. តើដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលអនុវត្តតាមជំហានដូចបានកំណត់ក្នុងសេចក្ដីណែនាំបច្ចេកទេសឬទេ ?
3. តើមានការវិភាគស្ថានភាពជាក់ស្ដែងដែរឬទេ ?
4. តើទិន្នន័យ និងព័ត៌មានដែលបានយកមកប្រើ គឺជាទិន្នន័យ និងព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពឬទេ ?
5. តើការវិភាគស្ថានភាព បានផ្ដោតលើបញ្ហារបស់ស្ត្រី បុរស កុមារ ជនពិការ យុវជន ឬក្រុមជនងាយរងគ្រោះជាក់លាក់ឬទេ ?
6. តើការវិភាគស្ថានភាព បានផ្ដោតលើបញ្ហាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុឬទេ ?
7. តើបានកំណត់អំពីបញ្ហាប្រឈម និងដំណោះស្រាយសមស្រប សម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ពិសេស ស្ត្រី បុរស កុមារ និងក្រុមជនងាយរងគ្រោះជាក់លាក់ឬទេ ?
8. ក្នុងការកំណត់តម្រូវការអភិវឌ្ឍន៍ តើមានការចូលរួមពីអ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ ឬតំណាងប្រជាពលរដ្ឋឬទេ ?
9. តើគម្រោងវិនិយោគដែលបានរៀបចំបានឆ្លើយតបទៅនឹងបញ្ហាប្រឈម ដូចរៀបរាប់នៅក្នុងការវិភាគស្ថានភាពឬទេ ?
10. តើគម្រោងអាទិភាពដែលមានថវិកាគាំទ្រ ឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់ប្រជាពលរដ្ឋ ពិសេស ស្ត្រី ឬបុរស ឬកុមារ ឬជនពិការ ឬក្រុមជនងាយរងគ្រោះជាក់លាក់ណាមួយឬទេ ?
11. តើគម្រោង ឬសកម្មភាព និងការប្រតិបត្តិការសេវារដ្ឋបាលនានា ឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍស្រុក និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានដែរឬទេ ?
12. តើជំពូកតាមដានត្រួតពិនិត្យ បានកំណត់អំពីយន្តការ និងវិធីសាស្ត្រសម្រាប់ការតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគឬទេ ?
13. តើសេចក្ដីព្រាងកម្មវិធីវិនិយោគបានយកទៅពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធឬទេ ?
14. តើគម្រោងដែលមានថវិកាគាំទ្រ មានគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តប៉ុន្មាន ? អរូបវន្តប៉ុន្មាន ?

ឧបសម្ព័ន្ធទី៦

# ជំនួយស្មារតី
# សម្រាប់ការរៀបចំសរសេរស្ថានភាពទូទៅ

នៅពេលសរសេរពីស្ថានភាពទូទៅ សក្តានុពល និងបញ្ហាប្រឈមរបស់មូលដ្ឋាន (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់) ក្រុមការងារកសាងផែនការត្រូវអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម ៖

**រៀបចំតារាងទិន្នន័យ**

តួលេខដែលយកមកបំពេញក្នុងតារាងសង្ខេបទិន្នន័យ ត្រូវស្រង់ចេញពីសៀវភៅទិន្នន័យភូមិ ឃុំ សង្កាត់ និងឯកសារព័ត៌មានស្ថានភាពមូលដ្ឋាន ដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយគេ។ តួលេខមួយចំនួនដូចជា ផ្ទៃដី ចំនួនឃុំ ចំនួនភូមិ គឺក្រុមការងារកសាងផែនការត្រូវបំពេញដោយខ្លួនឯង។ ក្រុមការងារអាចបន្ថែមព័ត៌មានផ្សេងទៀត ដែលខ្លួនយល់ថាមានសារៈសំខាន់ដល់ការរំលេចគុណភាពកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដូចជា សូចនាករនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅ និងចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តែមិនគួរបន្ថែមច្រើនពេកនាំឱ្យព័ត៌មានទាំងនោះប្រែទៅជាមិនសំខាន់ទៅវិញ។

ចំពោះឆ្នាំដំបូងនៃអាណត្តិក្រុមប្រឹក្សា ទិន្នន័យត្រូវយកទិន្នន័យឆ្នាំចាស់(ឆ្នាំកន្លងទៅ) ហើយទិន្នន័យនេះត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ដោយបន្ថែមកូឡោនតាមឆ្នាំនីមួយៗនៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល។

**ការសរសេរពីស្ថានភាពសេដ្ឋកិច្ច**

ក្នុងចំណុចនេះក្រុមការងារត្រូវធ្វើការកំណត់ និងសរសេរតាមបែបវិភាគអំពីសកម្មភាពសេដ្ឋកិច្ចចម្បងៗ និងបន្ទាប់បន្សំមួយចំនួន ដែលមានក្នុងមូលដ្ឋានដោយផ្អែកលើលទ្ធផលវិភាគផ្នែកសេដ្ឋកិច្ច។

សកម្មភាពសេដ្ឋកិច្ចចម្បង គឺសំដៅលើសកម្មភាពដែលប្រជាពលរដ្ឋភាគច្រើនអនុវត្ត ដើម្បីយកផលមកធ្វើជាកម្លាំងស្នូលក្នុងការទ្រទ្រង់ជីវភាពប្រចាំថ្ងៃ។ ចំណែកឯសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំ គឺសំដៅលើសកម្មភាពដែលប្រជាពលរដ្ឋមួយចំនួនអនុវត្តដើម្បីរកកម្រៃបន្ថែមសម្រាប់ការទ្រទ្រង់ជីវភាព(*ទោះបីជាបរិមាណចំណូលពីសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំអាចច្រើនជាងចំណូលពីសកម្មភាពសេដ្ឋកិច្ចចម្បងក៏ដោយ ក៏នៅតែចាត់ទុកថាជាសកម្មភាពសេដ្ឋកិច្ចបន្ទាប់បន្សំ*)។

**ឧទាហរណ៍** ៖ ក្នុងស្រុកដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបរបរជាអាជីវករលក់ដូរ ដូច្នេះសកម្មភាពសេដ្ឋកិច្ចចម្បងគឺអាជីវកម្ម ទោះបីជាចំណូលពីការលក់ដូររបស់ប្រជាពលរដ្ឋម្នាក់ៗអាចមានកម្រិតទាបជាងចំណូល ពីសកម្មភាពផ្សេងក៏ដោយ។ ក្រុមការងារត្រូវវិភាគស្ថានភាពអាជីវកម្មជាក់ស្តែងក្នុងស្រុកដោយពិនិត្យពីកត្តាអ្វីខ្លះដែលបានជំរុញ និងអ្វីខ្លះជាឧបសគ្គដល់ការឈានឡើងទាំងចំពោះមុខ និងយូរអង្វែងរបស់វិស័យនេះក្នុងស្រុក ហើយដែលកំពុងជះឥទ្ធិពលលើកម្រិតជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ ទន្ទឹមនេះ ត្រូវបរិយាយពីអ្វីខ្លះដែលនាំឱ្យមានការផ្លាស់ប្តូរក្នុងមុខរបរជំនួញ( ឧទាហរណ៍: កត្តាសេដ្ឋកិច្ចប្រែប្រួល) ហើយអ្វីខ្លះដែលស្រុកត្រូវធ្វើការព្យាយាមទប់ស្កាត់ ឬគ្រប់គ្រង ការផ្លាស់ប្តូរទាំងនេះ ដើម្បីធានានិរន្តរភាព និងភាពរីកចម្រើនក្នុងវិស័យនេះ។ ចំពោះស្រុកដែលមានប្រជាពលរដ្ឋភាគច្រើនប្រកបរបរធ្វើស្រែ សកម្មភាពសេដ្ឋកិច្ចចម្បងសម្រាប់ស្រុកនោះ គឺកសិកម្ម ទោះបីជាចំណូលបានមកពីការធ្វើស្រែរបស់ប្រជាកសិករម្នាក់ៗអាចតិចជាងចំណូលពីសកម្មភាពផ្សេងក៏ដោយ។

**សកម្មភាពចម្បង**

ក្នុងផ្នែកសេដ្ឋកិច្ច រួមមាន ៖

- **អាជីវកម្ម** ៖ មុខរបរសំខាន់ៗក្នុងវិស័យអាជីវកម្មរួមមាន មុខរបរជំនួញ ប្រភេទសិប្បកម្មនានា

ជាងជួសជុល។ល។ ក្នុងស្ថានភាពអាជីវកម្ម ត្រូវសរសេររៀបរាប់ពីសក្តានុពលសំខាន់ៗរបស់មូលដ្ឋាន និងបញ្ហាប្រឈមនានាដែលមូលដ្ឋានកំពុងជួបប្រទះ។

- **កសិកម្ម ៖** សកម្មភាពសំខាន់ៗក្នុងវិស័យកសិកម្មរួមមាន ការដាំដុះស្រូវ ដំណាំកសិ ឧស្សាហកម្ម និងដំណាំរួមផ្សំ ការចិញ្ចឹមសត្វនិងត្រី ការប្រើប្រាស់ជីធ្លី និងប្រព័ន្ធធារាសាស្ត្រដែលជួយគាំទ្រដល់ការងារកសិកម្ម។ ក្នុងស្ថានភាពកសិកម្ម ត្រូវសរសេររៀបរាប់អំពីសក្តានុពលសំខាន់ៗរបស់មូលដ្ឋាននិងបញ្ហាប្រឈមនានាកំពុងជួបប្រទះនៅក្នុងមូលដ្ឋាន។
- **ឧស្សាហកម្ម ៖** សកម្មភាពសំខាន់ៗក្នុងវិស័យឧស្សហកម្មរួមមាន សកម្មភាពសិប្បកម្ម រោងចក្រ និងការងារសំណង់ជាដើម។ ដូច្នេះ ត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗដែលពាក់ព័ន្ធនឹងវិស័យនេះ។
- **គមនាគមន៍ ៖** សរសេររៀបរាប់អំពីសក្តានុពលនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវគោក និងផ្លូវទឹកដែលស្រុកមាន និងបញ្ហាប្រឈមសំខាន់ៗដែលមូលដ្ឋានកំពុងជួបប្រទះ។
- **សេវាកម្ម ៖** សរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមនៃសេវាកម្មនានាពាក់ព័ន្ធនឹងសាធារណការ ទឹកស្អាត អគ្គិសនី ទីផ្សារ ទេសចរណ៍ ។ល។
- **ការវិនិយោគ ៖** ចំណុចនេះត្រូវសរសេររៀបរាប់អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងវិស័យឯកជនជាមួយស្រុកដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍នានាក្នុងស្រុក ដូចជាការអភិវឌ្ឍន៍ផ្សារ ចំណតរថយន្ត ផ្លូវ ស្ពាន និងគម្រោងអភិវឌ្ឍន៍ផ្សេងទៀត។ ដូច្នេះត្រូវសរសេររៀបរាប់ពីសក្តានុពល និងបញ្ហាប្រឈម ចម្បងៗដែលពាក់ព័ន្ធនឹងការវិនិយោគនេះ។
- **ការទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ៖** ត្រូវសរសេររៀបរាប់អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយពាណិជ្ជករ ឬក្រុមហ៊ុនក្នុងស្រុក ក្រៅស្រុក ឬកិច្ចសហប្រតិបត្តិការ ឬការចងសម្ព័ន្ធមេត្រីជាមួយអាជ្ញាធររដ្ឋបាលនានាដើម្បីអភិវឌ្ឍន៍មូលដ្ឋានដូចជា ការបង្កើតតំបន់អភិវឌ្ឍន៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការការពារទឹកជំនន់ និងការអភិវឌ្ឍទីផ្សារជាដើម។ ដូច្នេះត្រូវសរសេររៀបរាប់អំពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗដែលពាក់ព័ន្ធនឹងការងារទាំងនេះ។

ក្រៅពីចំណុចសំខាន់ដែលបានរៀបរាប់ខាងលើ ក្រុមការងារអាចបន្ថែមនូវចំណុចផ្សេងទៀត ដែលយល់ថាចាំបាច់ និងគួរបញ្ចូលក្នុងកម្មវិធីវិនិយោគ។ ការសរសេររៀបរាប់ចំណុចបន្ថែមនេះគឺដូចគ្នានឹងចំណុចនានាខាងលើដោយផ្តោតលើសក្តានុពល និងបញ្ហាប្រឈមនានា ។

**ការសរសេរពីស្ថានភាពសង្គមកិច្ច**

ស្ថានភាពសង្គមកិច្ចគឺជាផ្នែកមួយដែលត្រូវធ្វើការសិក្សាពីលក្ខណៈប្រជាសាស្ត្រ សេវាសាធារណៈផ្នែកសង្គម និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ ដូចជា៖ ស្ថានភាពអប់រំ សុខុមាលភាព យេនឌ័រ ភាពក្រីក្រ អំពើហិង្សា ការជួញដូរស្ត្រីនិងកុមារ ការលើកកម្ពស់សិទ្ធិមនុស្ស និងស្ថានភាពសាសនាជាដើម។ ពេលសរសេរអំពីស្ថានភាពសង្គមកិច្ច ត្រូវសរសេរតាមបែបវិភាគដោយផ្អែកលើលទ្ធផលនៃការវិភាគសង្គមកិច្ច និងត្រូវផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

- **អប់រំ ៖** សរសេរពីការសម្រេចបានរបស់វិស័យអប់រំ ដូចជា ការសិក្សារបស់កុមារ ស្តង់ដារអប់រំ (ការចូលរៀនរបស់កុមារនៅថ្នាក់មត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ ការបោះបង់ចោលការសិក្សា ការរៀនត្រួតថ្នាក់ ពិសេសក្មេងស្រី ការងារអក្ខរកម្ម...)។
- **សុខាភិបាល ៖** សរសេរពីស្ថានភាពសុខភាពរបស់ប្រជាជន ពិសេសស្ត្រីនិងកុមារ កម្រិតនៃការ

ទទួលបានសេវាសុខភាព អត្រាមរណភាពមាតានិងទារក គ្រោះថ្នាក់កើតពីជំងឺផ្សេងៗ និងបញ្ហានានាដែលពាក់ព័ន្ធនឹងសុខភាពមាតានិងកុមារ ទឹកស្អាត អនាម័យ បញ្ហាយុវវ័យ សុខភាពបន្តពូជ ។ល។

- **យេនឌ័រ ៖** គួរសរសេរពីការទទួលយកសេវា ការចូលរួមចំណែករបស់ស្ត្រីក្នុងការសម្រេចចិត្តនានា និងសកម្មភាពសង្គម និងការលំបាកដែលស្ត្រីកំពុងជួបប្រទះ(បុរសពុំបានជួប) ឬកត្តាទាំងឡាយក្នុងសង្គម ដែលនាំឱ្យស្ត្រីជួបការលំបាកញឹកញាប់ជាងបុរស។
- **ភាពក្រីក្រ ៖** សរសេរពីកម្រិតក្រីក្ររបស់ប្រជាជនដោយបង្ហាញពីមូលហេតុចម្បងៗដែលនាំឱ្យមានគ្រួសារមួយចំនួនធ្លាក់ខ្លួនក្រ មូលហេតុដែលគ្រួសារក្រីក្រមិនអាចកែលម្អជីវភាពរបស់ពួកគេបាន និងមូលហេតុដែលនាំឲ្យគ្រួសារក្រីក្របានកែលម្អជីវភាពខ្លួន។
- **សាសនា ៖** រៀបរាប់ពីប្រភេទសាសនា និងចំនួនភាគរយប្រជាពលរដ្ឋ ដែលកាន់សាសនានីមួយៗ។
- **អន្តោប្រវេសន៍ និងបំផ្លាស់ទីលំនៅ ៖** ត្រូវសរសេររៀបរាប់ពីស្ថានភាពនៃការបំផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋពីតំបន់ផ្សេងៗចូលមកមូលដ្ឋានខ្លួនដើម្បីប្រកបមុខរបរនានា ដូចជា ៖ ប្រកបមុខរបរជាកម្មកររត់ម៉ូតូឌុប កម្មកររោងចក្រ និងជនបរទេសដែលចូលមកជាអ្នកទេសចរ ឬមកប្រកបមុខរបរ។ ចំណុចនេះ ត្រូវសរសេររៀបរាប់ពីសក្តានុពល និងបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងស្ថានភាពទាំងនេះ។

ក្រៅពីស្ថានភាពសំខាន់ៗខាងលើ ក្រុមការងារអាចធ្វើការរៀបរាប់បន្ថែមពីស្ថានភាពផ្សេងទៀតដែលពាក់ព័ន្ធនឹងស្ថានភាពសង្គមកិច្ច តាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាន ដូចជាការលើកកម្ពស់សិទ្ធិកុមារ និងប្រជាពលរដ្ឋទូទៅ ការទប់ស្កាត់សកម្មភាពជួញដូរស្ត្រីនិងកុមារ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការជួយជនចាស់ជរាគ្មានទីពឹង និវត្តជន កុមារកំព្រាជនអនាថា។ល។

## ការសរសេរពីស្ថានភាពធនធានធម្មជាតិ និងបរិស្ថាន

ផ្នែកនេះត្រូវសរសេររៀបរាប់ពីអ្វីខ្លះដែលជាភាពខ្លាំង(សក្តានុពល)និងផលប្រយោជន៍ ដែលមានដូចជា ដីធ្លីនិងធនធានធម្មជាតិ និងអ្វីខ្លះដែលជាបញ្ហាប្រឈម ឬឧបសគ្គដែលកំពុងគំរាមកំហែងដល់ដីធ្លី ធនធានធម្មជាតិនិងបរិស្ថាន។ ទន្ទឹមនេះ ត្រូវសរសេររៀបរាប់ពីគ្រោះថ្នាក់ ការបាត់បង់ខូចខាត ការបំផ្លិចបំផ្លាញ ការប្រែប្រួល និងផលប៉ះពាល់ជាអវិជ្ជមានពីបាតុភូតទាំងឡាយកើតមានឡើង ដែលបង្កដោយមនុស្ស ឬដោយធម្មជាតិ។

ការសរសេរផ្នែកនេះត្រូវផ្អែកលើលទ្ធផលនៃការវិភាគការប្រើប្រាស់ដីធ្លី ការវិភាគធនធានធម្មជាតិ ការវិភាគបរិស្ថាន និងការវិភាគគ្រោះមហន្តរាយ ដោយផ្តោតលើ ៖

- **ការប្រើប្រាស់ដីធ្លី ៖** ត្រូវរៀបរាប់ពីបញ្ហាប្រឈមសំខាន់ៗ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីលំនៅដ្ឋាន ដីធ្វើស្រែ ដីចំការ ដីសម្រាប់ការវិនិយោគ ដីសម្បទាន តំបន់អភិរក្ស។ល។ ចំពោះការប្រើប្រាស់ដីសម្រាប់លំនៅដ្ឋាន ត្រូវរៀបរាប់ពីសក្តានុពលនិងបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការកំណត់ប្រភេទលំនៅដ្ឋាន ការផ្លាស់ប្តូរទីតាំង ការរៀបចំនិងគ្រប់គ្រងសំណង់អានាធិបតេយ្យ និងការរៀបចំប្លង់លំនៅដ្ឋានជាដើម។ល។
- **ធនធានធម្មជាតិ ៖** បរិយាយពីធនធានធម្មជាតិសំខាន់ៗ ដែលមាន ដូចជា ៖ ដីធ្លី ព្រៃឈើ សត្វព្រៃ ធនធានជលផល បឹង អូរ ស្ទឹង រ៉ែ...។ល។ ដែលប្រជាជនពឹងផ្អែកលើធនធានទាំងនេះសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគាត់។ ដូច្នេះ ត្រូវសរសេរពីកម្រិតនៃការប្រើប្រាស់ធនធានទាំងនេះ និងបញ្ហាប្រឈមចម្បងៗដែលកំពុងជួបប្រទះពាក់ព័ន្ធនឹងការប្រើប្រាស់នេះ។

- **បរិស្ថាន ៖** ត្រូវរៀបរាប់ពីសក្ដានុពលពាក់ព័ន្ធនឹងបរិស្ថាន ដូចជាកន្លែងហាត់ប្រាណ និងសួនឧទ្យានសាធារណៈ ទីលានចាក់សំរាម និងបញ្ហានានា ដែលគំរាមកំហែងលើបរិស្ថាន ដូចជាការបំពុលបរិយាកាស កាកសំណល់រឹង និងរាវ។ល។
- **គ្រោះមហន្តរាយចម្បងៗ ៖** រៀបរាប់ពីស្ថានភាពនៃការបំផ្លិចបំផ្លាញដោយសារខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ភ្លើងឆេះផ្ទះ គ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះ គ្រោះទឹកជំនន់។ល។
- **ការប្រែប្រួលអាកាសធាតុ ៖** រៀបរាប់ពីទឹកជំនន់ ភាពរាំងស្ងួត សីតុណ្ហភាពឡើងខ្ពស់ កម្រិតទឹកភ្លៀងមិនទៀងទាត់។

**ការសរសេរពីស្ថានភាពរដ្ឋបាល សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

ផ្នែកនេះត្រូវសរសេររៀបរាប់ដោយសង្ខេបពីចំណុចសំខាន់ៗដូចជា ៖ អភិបាលកិច្ច ការគ្រប់គ្រងដែនដី ស្ថិតិប្រជាជន កិច្ចការសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដោយផ្អែកលើលទ្ធផលនៃការវិភាគស្ថានភាពរដ្ឋបាលសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ ទិន្នន័យនិងព័ត៌មានមួយចំនួន ដែលត្រូវរៀបរាប់ក្នុងផ្នែកនេះ មានបង្ហាញក្នុងតារាងព័ត៌មានសំខាន់ៗ ដូចជា ផ្ទៃដី ចំនួនឃុំ ភូមិ និងស្ថិតិប្រជាជន ជាដើម។

- **អភិបាលកិច្ច ៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងអភិបាលកិច្ច។
- **គ្រប់គ្រងដែនដី៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំ និងគ្រប់គ្រងដែនដីរដ្ឋបាល ដូចជា៖ ការកំណត់ព្រំប្រទល់ដែនដីភូមិសាស្ត្ររដ្ឋបាល និងតំបន់សំខាន់ៗក្នុងមូលដ្ឋាន ការបង្កើតក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិថ្មី ការរៀបចំប្លង់គោលជាដើម។
- **ការគ្រប់គ្រងស្ថិតិ៖** រៀបរាប់ពីបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការចុះបញ្ជី និងការងារអត្រានុកូលដ្ឋាន។
- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** រៀបរាប់ពីភាពខ្លាំង និងបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រង ការរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ នៅតំបន់ទីប្រជុំជនសំខាន់ៗ។

**ចំពោះស្រុកជាប់ព្រំដែន គួរបញ្ចូលការងារព្រំដែន ៖** ភាពងាយស្រួល និងការលំបាកក្នុងការរៀបចំ និងគ្រប់គ្រងច្រកព្រំដែន និងកិច្ចសហការជាមួយប្រទេសជិតខាង។

**ឧបសម្ព័ន្ធទី៧**

## ឧបករណ៍
## វិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

ការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយទៅក្នុងកម្មវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្អែកលើសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំកម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ។ ដំណើរការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ត្រូវអនុវត្តឡើងតាំងពីដំណាក់កាលដំបូងនៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

នៅក្នុងការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ក្រុមការងារកសាងផែនការ គ.ផ.ថ និង ឬ អ្នកពាក់ព័ន្ធផ្សេងៗទៀត អាចប្រើប្រាស់ឧបករណ៍នានា ដូចខាងក្រោម ៖

### ១). ឧបករណ៍ទី១ ៖ ការគូសផែនទីហានិភ័យនៃគ្រោះមហន្តរាយ

ការរៀបចំផែនទីនេះនឹងជួយកំណត់ពីមុខសញ្ញាហានិភ័យនៃគ្រោះមហន្តរាយ ដែលបានកើតឡើងក្នុងមូលដ្ឋាន។ ការគូរផែនទីនឹងជួយដល់អ្នករៀបចំផែនការក្នុងការកំណត់នូវទីតាំង និងស្ថានភាពនៃភាពងាយរងគ្រោះ ដើម្បីឈានទៅធ្វើការវិភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ការគូសផែនទីនេះនឹងធ្វើឡើងនៅក្នុងកម្រិតឃុំ សង្កាត់ ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សា គ.ក.ន.ក ប្រធានភូមិ និងអ្នកពាក់ព័ន្ធនានា ដោយប្រើប្រាស់ផែនទីរដ្ឋបាលឃុំជាគោល។

ការគូសផែនទីត្រូវធ្វើឡើងជា៤ជំហាន ដូចខាងក្រោម ៖

- **ជំហានទី១ ៖** គូសគំនូសទ្រង់ទ្រាយរបស់រដ្ឋបាលឃុំ សង្កាត់ កំណត់ព្រំប្រទល់រដ្ឋបាលភូមិ រួចហើយអ្នកចូលរួមគូរបន្ថែមនូវទីតាំងលក្ខណៈធម្មជាតិដូចជា ទន្លេ បឹង ព្រៃ តំបន់អភិរក្ស ជាដើម។
- **ជំហានទី២ ៖** គូសបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធថ្មីៗដែលមានក្នុងមូលដ្ឋានទៅក្នុងផែនទី ដូចជា ៖
  - ផ្លូវ
  - អគារសាធារណៈ (វត្ត អគាររដ្ឋបាល សាលារៀន មន្ទីរពេទ្យ...)
  - ទំនប់ទឹក អាងស្តុកទឹក ប្រព័ន្ធធារាសាស្ត្រ អណ្តូងទឹក និងស្រះ
  - ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី (ម៉ាស៊ីនភ្លើង, ឋាមពលកកើតឡើងវិញ...)
  - ទីតាំងចាក់សំរាម ប្រព័ន្ធលូ
  - បូជនីយដ្ឋាន ជាដើម
- **ជំហានទី៣ ៖** ក្នុងជំហាននេះ អ្នកចូលរួមគូសផែនទីបញ្ជាក់ពីទីតាំងដែលទទួលរងផលប៉ះពាល់ពីគ្រោះធម្មជាតិ ដោយប្រើប្រាស់គំនូសតាងផ្សេងៗគ្នា ឬប្រើប្រាស់ពណ៌ជាសញ្ញាតាមការឯកភាពគ្នាក្នុងក្រុម។ ផលប៉ះពាល់អាចមានដូចជា តំបន់ដែលរងផលប៉ះពាល់ពី

ទឹកជំនន់ គ្រោះរាំងស្ងួត ព្យុះ សត្វល្អិតបំផ្លាញ ជម្ងឺរាតត្បាត ការឡើងកំដៅ និងតំបន់ឆ្នេរដែលមានរលកធំៗ ជាដើម។

- **ជំហានទី៤ ៖** អ្នកចូលរួមកំណត់ និងគូសលើផែនទីពីស្ថានភាពប្រែប្រួលនៃទិដ្ឋភាពពីមុន និងពេលបច្ចុប្បន្ន (ឧទាហរណ៍ ៖ ទំនប់តាមតំបន់ឆ្នេរ ការបាត់បង់ព្រៃ និងដីអភិរក្ស)។ ការប្រែប្រួលទាំងនេះអាចមានប្រភពខុសគ្នាៗដូចជា បណ្តាលមកពីការសម្រេចចិត្តផ្នែកនយោបាយ សង្គម សេដ្ឋកិច្ច ផលប៉ះពាល់ពីអាកាសធាតុ និងពីគ្រោះធម្មជាតិជាដើម។ ទោះជាមានហេតុផលខុសគ្នាក៏ដោយ ការប្រែប្រួលនៃបរិស្ថានធម្មជាតិ ក៏អាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការប្រែប្រួលអាកាសធាតុ ឬគ្រោះធម្មជាតិផងដែរ។

**តាមរយៈឧបករណ៍ទី១នេះ** អ្នកវិភាគអាចកំណត់បាននូវទីតាំងភូមិសាស្ត្រ ប្រភេទគ្រោះមហន្តរាយធម្មជាតិ ស្ថានភាពនៃការប្រែប្រួល និងមូលហេតុនានាដែលនាំឲ្យ មានការប្រែប្រួលស្ថានភាពគ្រោះធម្មជាតិតាមប្រភេទនីមួយៗ។ ឧបករណ៍ទី១នេះ នឹងត្រូវប្រើប្រាស់ជាមូលដ្ឋានក្នុងការអនុវត្តឧបករណ៍ផ្សេងៗទៀត។

## ២). ឧបករណ៍ទី២ ៖ ការវិភាគនិន្នាការ

ការវិភាគនិន្នាការ គឺជាឧបករណ៍សម្រាប់កំណត់នូវការប្រែប្រួលអាកាសធាតុសំខាន់ៗ និងព្រឹត្តការណ៍គ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុដែលកើតមានឡើង។ លទ្ធផលនៃការវិភាគនេះនឹងផ្តល់នូវព័ត៌មានអំពីគ្រោះមហន្តរាយអាកាសធាតុជាក់លាក់ និន្នាការនៃប្រភេទគ្រោះមហន្តរាយធម្មជាតិនីមួយៗ ភាពញឹកញាប់ ភាពធ្ងន់ធ្ងរ និងរបបនៃផលប៉ះពាល់។

ការអនុវត្តនូវឧបករណ៍វិភាគនិន្នាការនេះ ត្រូវធ្វើឡើងជាមួយប្រជាពលរដ្ឋ ដែលស្ថិតក្នុងតំបន់រងគ្រោះពីគ្រោះមហន្តរាយ (ផ្អែកលើផែនទីហានិភ័យគ្រោះមហន្តរាយ) ជនងាយរងគ្រោះ ស្ត្រី ចាស់ជរា និងជនក្រីក្រ ដោយបែងចែកជាក្រុមពិភាក្សាតូចៗយ៉ាងតិច៣ ដូចជាក្រុមស្ត្រី ក្រុមបុរស និងក្រុមអាជ្ញាធរ ឬច្រើនជាងនេះទៅតាមការចាំបាច់។ ការវិភាគធ្វើឡើងជា៣ជំហាន ដូចខាងក្រោម ៖

- **ជំហានទី១ ៖** អ្នកសម្របសម្រួលត្រូវសួរអំពីព្រឹត្តការណ៍គ្រោះមហន្តរាយទាក់ទងនឹងអាកាសធាតុ និងផលប៉ះពាល់ដែលពួកគេបានជួបប្រទះកន្លងមក ហើយយកទិន្នន័យនោះទៅបំពេញនៅក្នុងតារាងខាងក្រោមត្រង់ខ្ទង់ លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស (ដូចមានក្នុងតារាងខាងក្រោម)។
- **ជំហានទី២ ៖** អ្នកសម្របសម្រួលបន្តសាកសួរដល់អ្នកចូលរួមធ្វើការចាត់ថ្នាក់ភាពងាយរងគ្រោះដែលបានជួបប្រទះតាមឆ្នាំ ដែលបានកំណត់ទៅតាមមុខសញ្ញានៃគ្រោះមហន្តរាយនីមួយៗ។ ក្នុងការធ្វើចំណាត់ថ្នាក់នេះត្រូវដាក់ពិន្ទុ កម្រិតរងគ្រោះពី១ ដល់៥ (១.កម្រិតរងគ្រោះទាបបំផុត និង៥.ជាកម្រិតរងគ្រោះធ្ងន់ធ្ងរបំផុត)។
- **ជំហានទី៣ ៖** បន្ទាប់ពីការដាក់ពិន្ទុកម្រិតភាពរងគ្រោះហើយ ត្រូវបន្តពិនិត្យមើលលើនិន្នាការនៃផលប៉ះពាល់ទៅតាមមុខសញ្ញានីមួយៗ ហើយស្វែងរកនូវមុខសញ្ញាគ្រោះថ្នាក់

ណាមួយដែលកើតឡើងញឹកញាប់ និងកាន់តែធ្ងន់ធរ ដើម្បីធ្វើការវិភាគបន្តនៅក្នុងទម្រង់អក្សរ H។

តារាងវិភាគនិន្នាការ

| ប្រភេទគ្រោះធម្មជាតិ | និន្នាការ | | | | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | ១៩៨០-៨៩ | ១៩៩០-៩៩ | ២០០០-០៩ | ២០១០-បច្ចុប្បន្ន | |
| • រាំងស្ងួត | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • រដូវប្រាំងអូស បន្លាយ (លើសពី៣សប្តាហ៍) | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការខូតដំណាំ ដោយភាពរាំងស្ងួត | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការខូតដំណាំ ដោយទឹកជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការធ្លាក់ភ្លៀងខ្លាំង | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការកើនឡើងកម្រិតទឹកជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការអូសបន្លាយ រយៈពេលទឹក ជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការប្រែប្រួល អំឡុងពេលរដូវ ប្រាំង - វស្សា | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ។ល។ | | | | | |

**កំណត់សម្គាល់**

ក្នុងការអនុវត្តជាក់ស្តែង អ្នកវិភាគត្រូវពិចារណាលើកំណត់សម្គាល់ដូចខាងក្រោម ៖

- ប្រភេទគ្រោះធម្មជាតិ ៖ អាស្រ័យលើប្រភេទគ្រោះធម្មជាតិដែលបានកើតមានឡើងជាក់ស្តែងនៅក្នុងមូលដ្ឋាននីមួយៗ។
- ឆ្នាំ ៖ អាចកំណត់ ឬបែងចែកតាមជំនាន់ ឬរបប ឬឆ្នាំ ឬតាមការកំណត់ផ្សេងៗទៀត ដែលជាអាចឲ្យអ្នកចូលរួមងាយស្រួលក្នុងការរំលឹកឡើងវិញនូវនិន្នាការពាក់ព័ន្ធនឹងប្រភេទគ្រោះធម្មជាតិនីមួយៗ។

៣). **ឧបករណ៍ទី៣ ៖ ការវិភាគតាមទម្រង់** H

ឧបករណ៍ទម្រង់អក្សរ "H" គឺជាឧបករណ៍វាយតម្លៃដោយមានការចូលរួម ដែលពង្រឹងបន្ថែមលើលទ្ធផលនៃការវិភាគនិន្នាការ ហើយឧបករណ៍នេះមានគោលបំណងកំណត់ភាពប្រែប្រួលសំខាន់នៃអាកាសធាតុ និងព្រឹត្តការណ៍គ្រោះមហន្តរាយអាកាសធាតុ ព្រមទាំងផលប៉ះពាល់ក្នុងមូលដ្ឋាននៅតំបន់ជាក់លាក់ណាមួយ។ លើសពីនេះ ឧបករណ៍នេះក៏ជួយសម្រួលផងដែរក្នុងការកំណត់វិធានការបន្សុំាដែលសមស្របសម្រាប់សហគមន៍។ ក្នុងការអនុវត្តជំហាននេះ អ្នកវិភាគត្រូវអនុវត្តតាមជំហាននានា ដូចខាងក្រោម ៖

- **ជំហានទី១ "ការកំណត់ផលប៉ះពាល់នៃមុខសញ្ញាគ្រោះមហន្តរាយ"៖** សកម្មភាពក្នុងជំហាននេះ រួមមាន ៖
    - កំណត់ និងឯកភាពលើមុខសញ្ញា ឬប្រភេទគ្រោះមហន្តរាយធម្មជាតិ

- វិភាគនិន្នាការនៃមុខសញ្ញា ឬប្រភេទគ្រោះមហន្តរាយធម្មជាតិ ដោយសួរសំណួរគន្លឹះមួយចំនួន ដូចខាងក្រោម ៖
  + តើមានផលប៉ះពាល់អវិជ្ជមានអ្វីខ្លះ កើតចេញពីមុខសញ្ញានៃគ្រោះមហន្តរាយ?
  + តើមានដំណោះស្រាយអ្វីខ្លះ?
  + តើផលប៉ះពាល់ មានកម្រិតណា?
  + តើនៅក្នុងសហគមន៍មានធនធានអ្វីខ្លះ សម្រាប់ដោះស្រាយបញ្ហាប្រឈមផលប៉ះពាល់ទាំងនោះ?។ល។
- បន្ទាប់ពីសួរសំណួរគន្លឹះនានាហើយ អ្នកសម្របសម្រួលត្រូវ ៖
  + ស្រង់នូវផលប៉ះពាល់អវិជ្ជមានដែលបានលើកឡើងដោយអ្នកចូលរួមទៅក្នុងផ្នែកខាងឆ្វេងនៃតារាងទម្រង់ H
  + ស្រង់ពីធនធានដែលមានក្នុងសហគន៍ដាក់នៅផ្នែកខាងស្តាំនៃតារាងទម្រង់ H
  + ស្រង់អំពីដំណោះស្រាយដែលបានលើកឡើងនៅផ្នែកកណ្តាលនៃតារាងទម្រង់ H
- បន្ទាប់មកទៀត អ្នកសម្របសម្រួលស្នើសុំឲ្យអ្នកចូលរួមវាយតម្លៃពីកម្រិតផលប៉ះពាល់នៃមុខសញ្ញារងគ្រោះនោះចំពោះរូបគេ និងក្រុមគ្រួសារម្នាក់ម្តងៗ តាមរយៈការដាក់ពិន្ទុពី ១ជាកម្រិតទាប ដល់៥ដែលជាកម្រិតធ្ងន់ធ្ងរ។ រួចធ្វើការគណនាមធ្យមភាគពិន្ទុដែលអ្នកចូលរួមបានដាក់។

ការវិភាគតាមទម្រង់ H ទី១

បញ្ហា ៖ ....................................................

| ផលប៉ះពាល់ ៖ | ដំណោះស្រាយ<br><br>១ ២ ៣ ៤ ៥ | ធនធានដែលមាន ៖ |
|---|---|---|
| + | + | + |
| + | + | + |
| + | + | + |

- បន្ទាប់ពីអ្នកចូលរួមនីមួយៗបានដាក់ពិន្ទុលើកម្រិតនៃផលប៉ះពាល់ហើយ អ្នកសម្របសម្រួលត្រូវបូកសរុប និងគិតមធ្យមភាគលើពិន្ទុដែលបានកំណត់។ ពិន្ទុមធ្យមភាគដែលបានកំណត់ត្រូវប្រើប្រាស់ជាសូចនាករសម្រាប់តាមដានអំពីវឌ្ឍនភាពនៃការឆ្លើយតបទៅនឹងការបន្ស៊ាំការប្រែប្រួលអាកាសធាតុ និងជាលក្ខណៈវិនិច្ឆ័យមួយសម្រាប់ចាត់អាទិភាពលើបញ្ហាដែលត្រូវដោះស្រាយ។

- **ជំហានទី២ "ការកំណត់ផលប៉ះពាល់ពីការកើនឡើងទ្វេរដងនៃមុខសញ្ញាគ្រោះមហន្តរាយ" ៖** នៅក្នុងជំហានទី២នេះ អ្នកសម្របសម្រួលលើកឡើងថា ប្រសិនបើមុខសញ្ញានៃគ្រោះមហន្តរាយ (មុខសញ្ញាដែលបានវិភាគក្នុងជំហានទី១) កើនឡើងកាន់តែញឹកញាប់ ឬកើនឡើងទ្វេរដង តើប្រជាពលរដ្ឋម្នាក់ ឬគ្រួសារនីមួយៗនឹងទទួលផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ? ហើយគួរត្រូវមានដំណោះស្រាយយ៉ាងដូចម្តេច? អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់

អ្នកចូលរួមនៅក្នុងទម្រង់ H ដូចខាងក្រោម ៖

ការវិភាគតាមទម្រង់ H ទី២

បញ្ហា ៖ ..................................................

| ផលប៉ះពាល់ ៖ | ដំណោះស្រាយ ៖<br>១ ២ ៣ ៤ ៥ | |
|---|---|---|
| + | + | |
| + | + | |
| + | + | |

បន្ទាប់មក អ្នកសម្របសម្រួលស្នើឲ្យអ្នកចូលរួមដាក់ពិន្ទុលើកម្រិតផលប៉ះពាល់ ដូចជំហានទី១។ ទម្រង់អក្សរ Hទី២នេះនឹងជួយឲ្យអ្នកចូលរួមគិតប្រមាណទុកជាមុននូវភាពធ្ងន់ធ្ងរនៃអាកាសធាតុ ដែលអាចគម្រាមគំហែងដល់សហគមន៍ និងលើកយកដំណោះស្រាយកាន់តែមានប្រសិទ្ធភាពមួយកម្រិតថែមទៀត ក្នុងការបង្ការផលប៉ះពាល់ពីគ្រោះមហន្តរាយ កសាងភាពធន់ និងការបន្សាំខ្លួនរបស់សហគមន៍។

- **ជំហានទី៣ "ការកំណត់កត្តារាំង"** ៖ បន្ទាប់មកអ្នកសម្របសម្រួលបន្តពិភាក្សាអំពី ឧបសគ្គនានាដែលអាចកើតមានឡើង ដោយប្រើឧបករណ៍ទម្រង់អក្សរ H ទី៣។ ក្នុងការប្រើប្រាស់ឧបករណ៍ H ទី៣នេះ អ្នកសម្រសបម្រួល ផ្តោតលើកត្តារាំងនានា ដែលប្រជាពលរដ្ឋ ឬសហគមន៍មិនអាចបន្សាំទៅនឹងមុខសញ្ញានៃគ្រោះមហន្តរាយដែលត្រូវបានលើកឡើងមកនោះ។ ចម្លើយរបស់អ្នកចូលរួមត្រូវកត់ត្រាទុកនៅផ្នែកកណ្តាលនៃតារាង ហើយអ្នកចូលរួមត្រូវដាក់ពិន្ទុនៃកម្រិតកត្តារាំងនោះម្នាក់ម្តងៗពីលេខ១ជាកម្រិតតិចតួច ដល់លេខ៥ជាកម្រិតធ្ងន់ធ្ងរ។ ចុងបញ្ចប់ត្រូវគណនានូវពិន្ទុមធ្យមភាគនៃការដាក់ពន្ទុរបស់អ្នកចូលរួម។

ការវិភាគតាមទម្រង់ H ទី៣

បញ្ហា ៖ ..................................................

| | កត្តារាំង ៖<br>១ ២ ៣ ៤ ៥ | |
|---|---|---|
| | + | |
| | + | |
| | + | |

- **ជំហានទី៤ "ការកំណត់វិធានការ"** ៖ បន្ទាប់មកអ្នកសម្របសម្រួលបន្តពិភាក្សាអំពីសកម្មភាព ឬវិធានការនានា ដែលអាចជួយឲ្យប្រជាពលរដ្ឋ និងគ្រួសារនីមួយៗអាចបន្សាំទៅនឹងមុខសញ្ញានៃមហន្តរាយធម្មជាតិ ដូចដែលបានវិភាគក្នុងជំហានទី៣ ដោយសួរសំណួរគន្លឹះ ថា ៖
  - តើមានវិធានការបន្សាំអ្វីខ្លះដែលអាចជួយបង្កើនភាពធនរបស់សហគមន៍បាន ?
  - តើត្រូវធ្វើយ៉ាងដូចម្តេចខ្លះ ដើម្បីឲ្យទទួលបានពិន្ទុកាន់តែល្អជាងនេះ ?

ជាមួយគ្នានេះ អ្នកសម្របសម្រួលត្រូវស្រង់ចម្លើយនៃសំណួរទាំងនេះដាក់ក្នុងផ្នែកកណ្តាលនៃទម្រង់ H និងត្រូវស្រង់ដំណោះស្រាយនានាដែលបានកំណត់ក្នុងជំហានទី២ មកដាក់បញ្ចូល និងបន្សុីជាមួយគ្នា។ ព្រមទាំងធ្វើការដាក់ពិន្ទុដោយឯកភាពគ្នាជាក្រុមលើការទុកចិត្តនៃគម្រោង ឬដំណោះស្រាយដែលបានលើកឡើង ពីពិន្ទុ១ ដែលពិន្ទុទុកចិត្តខ្លាំងដល់ពិន្ទុ៥ ជាពិន្ទុមិនទុកចិត្តសោះ។

**ការគណនាពិន្ទុ៖**

ការគណនាពិន្ទុមធ្យមភាគនៃទម្រង់Hនីមួយៗ ត្រូវយកពិន្ទុសរុប ចែកនឹងចំនួនអ្នកដាក់ពិន្ទុ ឬគណនាតាមមធ្យាបាយផ្សេងៗទៀតតាមការចាំបាច់។

- **ជំហានទី៥ "ការរៀបចំគម្រោង" ៖** ក្រោយពីបានពិភាក្សាតាមក្រុមរួចរាល់ហើយ អ្នកសម្របសម្រួល យកលទ្ធផលនៃការកិច្ចពិភាក្សាក្រុមទាំងអស់ដាក់បញ្ចូលគ្នា ដោយស្រង់យកនូវដំណោះស្រាយនានាដែលបានលើកឡើង មករៀបចំជាគម្រោងបន្សុាំការប្រែប្រួលអាកាសធាតុ។ ចំណែកឯពិន្ទុនៃការពិភាក្សាក្នុងក្រុមនីមួយៗ ត្រូវយកមកបូកបញ្ចូលគ្នា ចែកនឹងចំនួនក្រុមពិភាក្សា នឹងបានជាពិន្ទុមធ្យមភាគផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុក្នុងឃុំសង្កាត់ ដែលត្រូវបានកំណត់ជាសូចនាករសម្រាប់តាមដានក្នុងឆ្នាំបន្ទាប់។ ក្រោយពីបានរៀបចំជាគម្រោងបន្សុាំការប្រែប្រួលអាកាសធាតុរួចរាល់ហើយ អ្នកវិភាគត្រូវជួបប្រជុំគ្នាជាថ្មី ដើម្បីធ្វើការចាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោង ដោយប្រើប្រាស់ឧបករណ៍ទី៤។

## ៤. ឧបករណ៍ទី៤ "ការធ្វើចំណាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោង"

ការចាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោងដែលបានលើកឡើង គឺជាការចាំបាច់ក្នុងការកំណត់នូវអាទិភាពនៃគម្រោងដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុសម្រាប់ការកៀរគរដៃគូគាំទ្រ។ ការចាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោងនីមួយៗធ្វើឡើងដោយផ្អែកលើសំណួរ និងកម្រិតដូចខាងក្រោម៖

- តើគម្រោងដែលស្នើអាចជួបប្រទះព្រឹត្តិការណ៍គ្រោះមហន្តរាយញឹកញាប់ប៉ុនណា?
  - មិនដែលជួបប្រទះ
  - កម្រនឹងជួបប្រទះ (តិចជាង០៥ឆ្នាំម្តង)
  - ជាញឹកញាប់ (យ៉ាងហោចណាស់២ទៅ៥ឆ្នាំម្តង)
  - តែងតែជួបប្រទះ (យ៉ាងហោចណាស់១ឆ្នាំម្តង)
- តើរំពឹងទុកថា អាចនឹងមានការខូចខាតអ្វីខ្លះ? (ជាការខូចខាតលើហេដ្ឋារចនាសម្ព័ន្ធ...)
  - មិនមាន
  - ខូចខាតតិចតួច
  - ខូចខាតទ្រង់ទាយ
  - ខូចខាតទាំងស្រុង

លទ្ធផលនៃការវិភាគនេះត្រូវយកមកផ្ទៀងផ្ទាត់នៅក្នុងតារាងដូចខាងក្រោម ៖

# តារាងការធ្វើចំណាត់ថ្នាក់ភាពងាយរងគ្រោះនៃគម្រោងបន្សាំការប្រែប្រួលអាកាសធាតុ

| ល.រ | ឈ្មោះគម្រោង | ប្រភេទ | ទីតាំង | ទីតាំងនៅក្នុងតំបន់ហានិភ័យ | | ភាពញឹកញាប់នៃផលប៉ះពាល់ | | | | ការខូចខាត | | | | ប្រភេទនៃភាពងាយរងគ្រោះ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មាន | មិនមាន | មិនដែល | កម្រមាន | ញឹកញាប់ | ជាប្រចាំ | មិនមាន | ខូចខាត តិចតួច | ខូចខាតខ្លាំង | ខូចទាំងស្រុង | |
| | | | | | | x | | | | x | | | | មិនមានហានិភ័យ |
| | | | | | | | X | | | | x | | | មានហានិភ័យទាប |
| | | | | | | | | X | | | | x | | មានហានិភ័យមធ្យម |
| | | | | | | | | | x | | | | x | មានហានិភ័យខ្ពស់ |
| | | | | | | | X | | | x | | | | មិនមានហានិភ័យ |
| | | | | | | | X | | | | | x | | មានហានិភ័យមធ្យម |
| | | | | | | | X | | | | | | x | មានហានិភ័យខ្ពស់ |
| | | | | | | | | X | | x | | | | មិនមានហានិភ័យ |
| | | | | | | | | X | | | x | | | មានហានិភ័យមធ្យម |
| | | | | | | | | X | | | | | x | មានហានិភ័យខ្ពស់ |
| | | | | | | | | | x | x | | | | មិនមានហានិភ័យ |
| | | | | | | | | | x | | x | | | មានហានិភ័យខ្ពស់ |
| | | | | | | | | | x | | | x | | មានហានិភ័យខ្ពស់ |